Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger


កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៧ | ថ្ងៃទី០១- ៣១ ខែមករា ឆ្នាំ២០១៥ លក់តម្លៃ ១០០០រៀល | លេខ ៨៣




## ឆ្នាំ ២០១៤ កម្ពុជាចាប់ផ្តើមដោយប្រទាំងប្រទើស តែឆ្នាំ២០១៥ ពលរដ្ឋសុំកុំឲ្យមានអ្វីកើតឡើងដូចឆ្នាំចាស់ថែមទៀត

ទំព័រ ១០-១១...

### សេចក្តីជូនដំណឹង

គណៈកម្មការសម្រាប់កិច្ចការមរណសាក្សីនៅកម្ពុជា សូមជម្រាបដល់បងប្អូនគ្រីស្តបរិស័ទទាំងអស់ឲ្យបានជ្រាបថា បច្ចុប្បន្នគណៈកម្មការយើងខ្ញុំកំពុងធ្វើ និង ចងក្រងសំណុំឯកសារអំពីមរណសាក្សីនៃព្រះសហគមន៍កាតូលិក។ សូមបងប្អូនសហការផ្តល់ជាព័ត៌មានមកកាន់ ៖ លោកឿង ឆ័ត្រ សិរី ( Fr. RoeungChatsirey )។ Tel: ០៧៧ ៨០០ ២១១ និង ០៩៦ ៣៤ ២២ ១៤៤


អ៊ីម៉ែល ៖ martyrscambodia@gmail.com | ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ

# តើសិទ្ធិក្នុងការបញ្ចេញមតិ ត្រូវតែហាមប្រាម ?



លោក **លី សុវណ្ណា** ចាងហ្វាង
កាសែតអ្នកនាំសារ

ក្នុងមួយរយៈពេលចុងក្រោយនេះ បន្ទាប់ពីមានភារវកម្មដែលបានសម្លាប់មនុស្សជាង ១០នាក់ និង មួយចំនួនទៀតបានរងរបួស ដែលបង្កឡើងដោយពួកឥស្លាមបំបែករដ្ឋ (ISIS) នៅក្នុងអាគារទស្សនាវដ្ដី ឆាលីហាបដូ នៅក្នុងទីក្រុងប៉ារីសប្រទេសបារាំង ។ ព្រឹត្តការណ៍នេះ បានធ្វើឲ្យមានភាពរំជើបរំជួលយ៉ាងខ្លាំងនៅទ្វីបអឺរ៉ុប ។ កាន់តែរំជើបរំជួលថែមទៀត បន្ទាប់ពីទស្សនាវដ្ដី ឆាលីហាបដូ បានចេញផ្សាយដែលមានរូបថ្លុករបស់ មហាម៉ាត់ ដែលជាព្យាការីរបស់ជនឥស្លាមនៅទំព័រមុខ។ ការចុះផ្សាយនេះ ត្រូវបានជនឥស្លាមស្ទើរពេញពិភពលោកមានប្រតិកម្មប្រឆាំង នឹងការចុះផ្សាយបែបនេះ។ ពួកគេតម្រូវឲ្យ ទស្សនាវដ្ដីធ្វើការកែតម្រូវ និង សុំអភ័យទោសដល់ជនឥស្លាមទាំងអស់ ព្រោះគេបានចាត់ទុកថា នេះជាការប្រមាថដល់សាសនាឥស្លាម។ ព្រឹត្តការណ៍នៃការតវ៉ានេះក៏បាន បង្កឲ្យមានអំពើហិង្សា នាំឲ្យមនុស្សស្លាប់មួយចំនួនថែមទៀតផង ដែលជាគ្រីស្តបរិស័ទកាតូលិក។

ព្រឹត្តិការណ៍នេះ នាំឲ្យយើងកាន់តែឆ្ងល់ថែមទៀតថាតើសេរីភាពបញ្ចេញមតិរបស់អ្នកសារព័ត៌មាន គួរតែត្រូវបានបិទដោយការគំរាមកំហែង?

នៅក្នុងសង្គមប្រជាធិបតេយ្យ អំណាចសារព័ត៌មាន ត្រូវបានគេចាត់ទុកថា ជាអំណាចទី៤ ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គម ។ វាជាកញ្ចក់ ជាអ្នកឃ្លាំមើល ។ល។ គេត្រូវតែទទួលស្គាល់ទាំងអស់គ្នា។ អ្នកសារព័ត៌មាន ត្រូវតែមានសេរីភាពក្នុងការបញ្ចេញមតិ ទស្សនៈរបស់ខ្លួនដោយសេរី គឺគ្មានអ្វីអាចគាបសង្កត់បានឡើយ ឬក៏ទទួលរងនូវការដាក់ទណ្ឌកម្ម ព្រោះតែការបញ្ចេញមតិដែរ ។ ការបញ្ចេញមតិរបស់គេ គឺដើម្បីសន្តិភាព ការអភិវឌ្ឍ និង កែលំអរសង្គម។ ប៉ុន្តែអ្នកសារព័ត៌មានក៏មានក្រមសីលធម៌របស់ខ្លួន អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ គោរពច្បាប់ និង សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិផងដែរ។ អ្នកសារព័ត៌មានក៏ត្រូវបានហាមប្រាមផងដែរ នូវការផ្សព្វផ្សាយព័ត៌មានមិនពិត ញុះញង់បង្កសង្គ្រាម បង្កភាពចលាចល អសន្តិសុខដល់សង្គម ដែលនាំមហន្តរាយជាដើម។

សិទ្ធិបញ្ចេញមតិ មិនមែនមានតែចំពោះ អ្នកសារព័ត៌មានប៉ុណ្ណោះទេ ពលរដ្ឋទូទៅក៏ទទួលបានសិទ្ធិនេះដែរ ព្រោះជាអ្វីដែលមនុស្សគ្រប់រូប ត្រូវតែទទួល ពេលគេមានជីវិតរស់នៅលើផែនដីនេះ។ ហេតុនេះ គ្មានក្រុមណាមួយ ឬបុគ្គលណាមួយ បញ្ចេញមតិរបស់ខ្លួន ដើម្បីបិទសំឡេងរបស់ក្រុមមួយ ឬ បុគ្គលម្នាក់ទៀតបាននោះទេ។ ការបញ្ចេញមតិទាំងឡាយក៏ត្រូវស្ថិតលើព្រំដែននៃក្រមសីលធម៌ និង គោរពសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិទៅវិញទៅមក។

ការតវ៉ានានា ការសម្ដែងមតិនានាដែលមានលក្ខណៈជេរប្រមាថ បង្អាប់បង្អោន បង្កឲ្យមានអំពើហិង្សា បង្កជាជម្លោះ បង្កមហន្តរាយដល់អ្នកដទៃ និងសង្គម ឬមហន្តរាយដល់ក្រុមមួយផ្សេងទៀត វាលែងជាការបញ្ចេញមតិទៀតហើយ។ វាទៅជាការបង្កអសន្តិសុខ ចលាចល ដែលនាំឲ្យគ្រោះថ្នាក់ដល់សង្គមទាំងមូល។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា ៖ "ការបញ្ចេញមតិរបស់បុគ្គលម្នាក់ តែងតែនាំឲ្យបុគ្គលម្នាក់ទៀតខឹងជារឿងធម្មតា។ ប៉ុន្តែបុគ្គលម្នាក់មិនអាចបញ្ចេញមតិដើម្បីបង្កជម្លោះ ឬដើម្បីមាក់ងាយជំនឿសាសនារបស់ម្នាក់ទៀតឡើយ ហើយក៏មិនអាចបញ្ចេញមតិ យកសាសនាម្នាក់ទៀតមកលេងសើចដែរ។ សិទ្ធិបញ្ចេញមតិ គឺមានក្នុងជីវិតពិតរបស់មនុស្សម្នាក់ៗហើយវាក៏ត្រូវតែសម្ដែងចេញដោយប្រុងប្រយ័ត្នដែរ។ របៀបដែល យើងនិយាយ ត្រូវតែមានការគួរសម និងប្រុងប្រយ័ត្ន។ ភាពប្រុងប្រយ័ត្ន គឺជាគុណធម៌របស់មនុស្សដែលនាំឆ្ពោះទៅរកមិត្តភាព។ ហេតុនេះ សេរីភាពក្នុងបញ្ចេញមតិត្រូវដើរទន្ទឹមគ្នានឹងគុណធម៌ និង ភាពប្រុងប្រយ័ត្ន។"




## ប្រតិទិន ព្រះគម្ពីរ ២០១៥

យើងខ្ញុំជាគណៈកម្មការព្រះគម្ពីរកាតូលិកកម្ពុជា សូមជម្រាបជូនដំណឹងដល់បងប្អូនឲ្យបានជ្រាបថា យើងមានលក់ **ប្រតិទិន ២០១៥** ដែលបងប្អូនចង់ជាវ យើងខ្ញុំលក់ក្នុងតំលៃ ៣០០០រៀល ។ ទំនាក់ទំនង ៖
សំ បញ្ញា ០៩២ ៦១៨ ០០២ (ភ្នំពេញ) ។ វឿត រ៉ាវុទ្ធ ០៩៣ ៦០៤ ៥៨៨ (បាត់ដំបង) ។ លួន ស្រីទី ០៩៧ ៦៨ ៥៩៤៩០(កំពង់ចាម)។

**Biblical Calendars 2015**

*The Cambodia Catholic Bible Committee has the pleasure to inform you that you can now buy the Biblical Calendars 2015 in very good price!*
*To buy or order for your parish or community please contact Mr. Panhnha 092 618 0021 Calendars: 0.75$*

**The new calendar of the Bible Committee is now available ! (3000r only)**

*You can order some for your parish or community . Phnom Penh : Mr. Sam Panhnha at 092 618 002 .*
*- Battambang, Mr. Voeut Ravuth (093 604 588 / 097 766 9480)*
*- Kompong Cham Ms. Loun Srey Thi (097 685 9490) are the contacts to buy this calendar.*
*With warmest regards, we wish you a holy year 2015 ! Fr. Vincent and the CCBC (Cambodian Catholic Bible Committee)*



Radio Veritas Asia
Crossing Borders, Sharing Christ

**វិទ្យុវ៉ារីតាស់អាស៊ី (RVA)ផ្សាយតាមរលកធាតុអាកាសខ្លី (SW)**
**ភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃ :**
ពីម៉ោង៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។
ស្ដាប់វិទ្យុវ៉ារីតាស់អាស៊ី (RVA) លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើនទាក់ទងនឹង ជីវិតរស់នៅប្រចាំថ្ងៃ សង្គម និងព័ត៌មាននានាពីព្រះសហគមន៍កាតូលិកកម្ពុជា។



**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក**
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ
**Tel/Fax** : (855) 23 224 120
**Email** : csccambodia@gmail.com / **Website** : www.catholiccambodia.org
**ចាងហ្វាង : លោក លី សុវណ្ណា**
Licence ៣៧០ ពម.ប្រក./ ២៤-មិថុនា-២០១០

CARITAS CHRISTI URGET NOS

# ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

## សូមគោរពជូនលោកអគ្គរាជទូតជាទីគោរព

ក្នុងនាមខ្ញុំផ្ទាល់ និងក្នុងនាមព្រះសហគមន៍កាតូលិកទាំងមូលនៅព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមរំលែកទុក្ខព្រួយរបស់ប្រជាជនបារាំងដែលត្រូវរងគ្រោះដោយភេរវកម្មដ៏សែនព្រៃផ្សៃហួសហេតុរកនិយាយមិនកើត។

ក្នុងឱកាសចូលឆ្នាំអន្តរជាតិនេះ យើងតែងតែជូនពរគ្នាទៅវិញទៅមក សូមឲ្យបានសេចក្តីសុខសាន្ត និងសុភមង្គល ទើបភេរវកម្មទាំងនោះដែលហួរពីសម្ចប់ និងពីការសងសឹកបន្ទាបបន្ថោកកិត្តិយសដ៏ថ្លៃថ្នូរនៃជីវិតមនុស្សយើង និង បន្ទាបបន្ថោកសេរីភាព និងភាតរភាពផង។

ព្រះសហគមន៍កាតូលិកទាំងមូល អង្វរព្រះបិតាសូមព្រះអង្គប្រទានឲ្យព្រះវិញ្ញាណ បើកចិត្តគំនិតមនុស្សលោកឲ្យមានប្រាជ្ញាសុខចិត្តនិយាយគ្នា សន្ទនាគ្នា ដើម្បីកសាងពិភពលោកប្រកបដោយសន្តិភាព និងយុត្តិធម៌។ ក្នុងពិភពលោកថ្មីនោះមនុស្ស នឹងមានសិទ្ធិសេរីភាពបញ្ចេញយោបល់ប្លែកៗពីគ្នា ដោយគ្មាននរណាយកការប្លែកៗពីគ្នានោះមកធ្វើជាលេសប្រព្រឹត្តអំពើអមនុស្សធម៌និងព្រៃផ្សៃហួសហេតុ។

យើងក៏សូមអង្វរព្រះបិតាសូមព្រះអង្គប្រទានសេចក្តីសុខសាន្តដល់វិញ្ញាណក្ខ័ន្ធអ្នករងគ្រោះសូមព្រះអង្គលើកទឹកចិត្តសាច់សាលោហិតអ្នករងគ្រោះទាំងនោះផង។

សូមលោកអគ្គរាជទូតជ្រាបថា ខ្ញុំសូមរួមចិត្តគំនិតជាមួយលោកនៅពេលរបបប្រជាធិបតេយ្យ និងពិភពលោកទទួលគ្រោះកាច ទោះបីមនុស្សលោកប៉ងប្រាថ្នាចង់រស់នៅ ដោយសុខដុមរមនា និងដោយមានជាតិនានាចុះសម្រុងគ្នា។

សូមលោកទទួលគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ភ្នំពេញថ្ងៃទី៨ មករាឆ្នាំ ២០១៥

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ
APOSTOLIC VICARIATE PHNOM PENH

+អូលីវីយេ ឝ្មីតហាស្លេ

*អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ*

# ឆ្នាំ២០១៥នេះ ពលរដ្ឋកម្ពុជាត្រូវប្រឈមមុខនឹងបំណុលបរទេសម្នាក់ប្រមាណជាជិត៤០០ដុល្លារ



អគារខ្ពស់ៗនិងផ្ទះប្រជាជននាទីក្រុងភ្នំពេញ។ ដោយគុយ លីហៀង

ឆ្នាំ២០១៤ កន្លងទៅនេះ កម្ពុជាបានបញ្ចប់ជាមួយនឹងកំណើនសេដ្ឋកិច្ចដែលគេប៉ាន់ប្រមាណថា នៅក្នុងកំរិតលើសពី ៧ ភាគរយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ បំណុលដែលពលរដ្ឋកម្ពុជាម្នាក់ៗ ដែលត្រូវជំពាក់បរទេសក៏កើនឡើងផងដែរ ។

សម្តេចតេជោ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍នៅក្នុងសារលិខិតអបអរសាទរពិធីបុណ្យចូលឆ្នាំសាកល ឆ្នាំ២០១៥ ថា ឆ្នាំ២០១៤ដែលបានកន្លងផុតទៅនេះ កម្ពុជាបានអនុវត្ត និងសម្រេចបានប្រកបដោយ ជោគជ័យនូវសមិទ្ធិផលធំៗជាច្រើនជូនជាតិ និង ប្រជាជន ដោយរក្សាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម ស្ថិរភាពហិរញ្ញវត្ថុ និងលំនឹងនៃម៉ាក្រូសេដ្ឋកិច្ច។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ទៀតថា កម្ពុជាត្រូវបានវាយតម្លៃថាជាប្រទេសទី១១លើពិភពលោក ដែលសំរេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់រយៈពេល១០ឆ្នាំចុងក្រោយ និង ជាប្រទេស ទី៥ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍ ដែលអាចសំរេចបាន នូវគោលដៅអភិវឌ្ឍសហសវត្សរ៍ក្នុង ចំណាត់ថ្នាក់ទី១នៅអាស៊ីប៉ាស៊ីហ្វិក ដែលសំរេចបាននូវវឌ្ឍនភាពល្អប្រសើរ ក្នុងការកែលំអរសូចនាករ ផ្នែកសង្គមកិច្ច ជាពិសេសការកាត់បន្ថយភាពក្រីក្រ ក្នុងអត្រាជាង ១ ភាគរយក្នុងមួយឆ្នាំ ។

សម្តេចតេជោ ហ៊ុន សែន ក៏បានមានប្រសាសន៍បន្ថែមទៀតថា ចាប់តាំងពីឆ្នាំ២០១០ ដល់ឆ្នាំ ២០១៣ សេដ្ឋកិច្ចកម្ពុជា បានទទួលកំណើនជាមធ្យមប្រចាំឆ្នាំ ៧ភាគរយ ហើយនៅក្នុងឆ្នាំ២០១៤កន្លងទៅនេះ តាមការប៉ាន់ស្មានកំណើនសេដ្ឋកិច្ច អាចសំរេចបានក្នុងរង្វង់ ៧ ភាគរយដែរ ក្នុងនោះ វិស័យឧស្សាហកម្ម កើន ៩,៦ភាគរយ វិស័យសេវាកម្មកើន ៧,៥ ភាគរយ និងវិស័យកសិកម្មកើន២,៦ ភាគរយ ដូច្នេះ នៅក្នុងឆ្នាំ២០១៥ កម្ពុជាក៏រំពឹងថា នឹងអាចទទួលបានកំណើនសេដ្ឋកិច្ចនៅក្នុងរង្វង់ ៧ភាគរយផងដែរ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ទៀតថា ផលិតផលក្នុងស្រុកសម្រាប់ពលរដ្ឋកម្ពុជាម្នាក់ៗ គឺកើនដល់ ១.១៣០ ដុល្លារ ដែលធ្វើឲ្យកម្ពុជា អាចនឹងចេញផុតពីប្រទេសដែលមានចំណូលទាប ហើយទៅជាប្រទេស ដែលមានចំណូលមធ្យមកំរិតទាបក្នុងពេលដ៏ខ្លីខាងមុខ រីឯអត្រានៃភាពក្រីក្រវិញ គឺត្រូវបានកាត់បន្ថយមកនៅក្រោម ១៨ ភាគរយនៅក្នុងឆ្នាំ២០១៤ នេះផងដែរ ។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា "នេះសរបញ្ជាក់ឲ្យឃើញថា សេដ្ឋកិច្ចកម្ពុជា កំពុងតែរីកចំរើននៅក្នុងទិសដៅដ៏ត្រឹមត្រូវ និងកាន់តែមានភាពមាំមួនឡើង ឈានឆ្ពោះទៅសំរេចបាន នូវគោលដៅ កំណើនសេដ្ឋកិច្ច ក្នុងអត្រាប្រមាណជា ៧ ភាគរយ ក្នុងមួយឆ្នាំ ប្រកបដោយចីរភាពសម្រាប់រយៈពេលមធ្យម។"

នេះគឺជារឿង គួរឲ្យមោទនៈភាពសម្រាប់កម្ពុជា ហើយវាក៏ជារឿងដែលមោទនភាពមួយទៀត ដែលស្ថាប័នហិរញ្ញវត្ថុធំៗដូចជា ធនាគារពិភពលោកជាដើម ដែលបានព្យាករណ៍អំពីភាពវិជ្ជមាននៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ។

ធនាគារពិភពលោក បានអះអាងថានៅក្នុងរបាយការណ៍មួយដែលបានផ្សព្វផ្សាយកាលពីពេលថ្មីៗកន្លងទៅនេះ បានឲ្យដឹងថា នៅក្នុងឆ្នាំ២០១៤ នេះ កម្ពុជាទទួលបានកំណើនសេដ្ឋកិច្ច ៧,២ ភាគរយ ហើយនៅក្នុងឆ្នាំ ២០១៥ គឺរង្វង់ ៧ ភាគរយដែរ។

ស្ថាប័នហិរញ្ញវត្ថុដដែល បានឲ្យដឹងទៀតថា ផលិតផលនៅក្នុងស្រុកសរុបរបស់កម្ពុជា គឺមានតម្លៃរហូតដល់ទៅ៣៧,១ ពាន់លានដុល្លារ នៅក្នុងនោះ ពលរដ្ឋកម្ពុជាម្នាក់ៗ មានអត្រាផលិតផលនៅក្នុងស្រុក សរុបនេះចំនួនប្រមានជា ២,៤៩៤ ដុល្លារ ពោលគឺខ្ពស់ជាងរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ប៉ុន្តែក្រៅពីនេះ បញ្ហាបំណុលបរទេស ដែលកម្ពុជាជំពាក់បរទេស ក៏មានការកើនឡើងផងដែរ ។

ប្រភពដដែលបានអះអាងថា នៅក្នុងឆ្នាំ២០១៤ កន្លងទៅនេះ កម្ពុជាជំពាក់បំណុលបរទេស ប្រមាណជា ៥.៥៥៩ លានដុល្លារ ហើយនៅក្នុងឆ្នាំ២០១៥ បំណុលនេះ នឹងឡើងដល់ទៅ ៥.៩៤៩ លានដុល្លារ ដូច្នេះ នៅក្នុងចំណោមពលរដ្ឋកម្ពុជា១៤,៩ លាននាក់ ពលរដ្ឋកម្ពុជាម្នាក់ៗគឺត្រូវជាប់បំណុលបរទេសដោយប្រយោលគឺប្រមាណជាពី៣៧០ដុល្លារ នៅក្នុងឆ្នាំ ២០១៤ និង កើនដល់ទៅជិត ៤០០ ដុល្លារ នៅក្នុងឆ្នាំ២០១៥ ។

ជុំវិញបញ្ហានេះ លោក ជុំ សាមិត្តជាប្រជាពលរដ្ឋម្នាក់ នៅក្នុងសង្កាត់ផ្សារដេប៉ូ ទី ៣ បានឲ្យដឹងថា ឲ្យតែឮអំពីបំណុល ពលរដ្ឋកម្ពុជាមិនសប្បាយចិត្តទេ ពីព្រោះវប្បធម៌ខ្មែរមិនប្រដៅមនុស្ស ឲ្យក្លាយខ្លួនជាកូនបំណុលគេឡើយ ប៉ុន្តែនៅក្នុងពេលបច្ចុប្បន្ន ជាពិសេសតាមទ្រឹស្តីសេដ្ឋកិច្ចគឺវាផ្ទុយគ្នា ពីព្រោះបំណុលនេះគឺជាដើមទុនមួយសម្រាប់វិនិយោគ ។

លោកបានបញ្ជាក់ថា "សម្រាប់ខ្ញុំ ៤០០ ដុល្លារ នៅក្នុងមួយឆ្នាំ ខ្ញុំមិនទុទិដ្ឋិនិយមទេ ឲ្យតែបំណុល ៤០០ ដុល្លារម្នាក់នេះ ត្រូវបានគេយកទៅប្រើប្រាស់ឲ្យចំគោលដៅ ត្រឹមត្រូវតម្លាភាព និងគ្មានអំពើពុករលួយ"។

លោក ជ័យ ថាវី អ្នករត់ម៉ូតូឌុបមួយរូបបានអះអាងថា សម្រាប់អ្នកមាន ៤០០ ដុល្លារ មិនច្រើនទេ នាពេលបច្ចុប្បន្ន តែសម្រាប់លោកជាអ្នករត់ម៉ូតូឌុប គឺច្រើនណាស់។

លោកបានបញ្ជាក់ថា "ខ្ញុំមិនសប្បាយចិត្តទេ ពេលដែលនៅសុខៗឮថា ជំពាក់លុយគេមួយឆ្នាំ ៤០០ ដុល្លារ ដោយអត់ដឹងអីនោះ"។

តាមរបាយការណ៍មួយ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានឲ្យដឹងថា បំណុលដែលកម្ពុជាជំពាក់បរទេស គឺជាបំណុលដែលកម្ពុជាខ្ចីគេ សម្រាប់យកមកបំពេញនូវដំណើរការអភិវឌ្ឍផ្សេងៗ នៅក្នុងប្រទេសដូចជា ស្ពាន ផ្លូវ ធារាស្រាស្ត្រ និងកម្មវិធីផ្សេងៗទៀតជាច្រើន សំដៅវិនិយោគ និងកសាងពង្រឹងសមត្ថភាពពលរដ្ឋកម្ពុជា នៅក្នុងការជំរុញកំណើនសេដ្ឋកិច្ច ៕

**ដោយ អរិយបុត្រ**

# បទពិសោធន៍ដែលយុវជនគួរតែដឹងអំពីការសេពគប់



យុវជនកំពុងពិភាក្សាជាមួយគ្នានៅកន្លែងមួយនាទីក្រុងភ្នំពេញ។ ដោយគុយ លីហៀង

ការសេពគប់ គឺជារឿងមួយដែល សំខាន់បំផុត ដែលយុវជនគួរតែដឹង ហើយរៀបចំខ្លួនឲ្យហើយ ពីព្រោះថា ការសេពគប់នេះក៏ជាកត្តាដែលសំខាន់ សម្រាប់កំណត់អំពីអនាគតរបស់ខ្លួន ផងដែរ នេះបើតាមបទពិសោធន៍ នៃ ជីវិតរបស់បុរសវ័យ៣៥ ឆ្នាំមួយរូប ។

លោក គាំ វាសនា ជាកម្មករចល័ត និងជាអ្នករត់ម៉ូតូឌុប វ័យ៣៥ ឆ្នាំមួយ រូបបានអះអាងថា លោកគឺជាអតីត កូនប្រុសនៅក្នុងគ្រួសារអ្នកដែលមាន ទ្រព្យធនមធ្យមមួយ នៅក្នុងខេត្តកំពង់ស្ពឺ ដែលមានឪពុកជាមន្ត្រីរាជការ និង ម្ដាយគឺជាអ្នកដែលរកស៊ី និង មេផ្ទះ ប៉ុន្តែមូលហេតុ ដែលលោក ធ្លាក់ខ្លួនជាកម្មករ ធ្វើការចិញ្ចឹមជីវិត និង គ្រួសារ ដោយសារតែរបរលក់ កម្លាំងពលកម្មបែបនេះ គឺដោយសារ តែការសេពគប់នេះឯង ។

លោក វាសនា បានចែករំលែក បទពិសោធន៍ ដែលលោកបានជួប ប្រទះ នៅក្នុងរលកជីវិតចុងក្រោយ របស់លោកនារយៈពេល ១៣ ឆ្នាំចុង ក្រោយថា លោកគឺជាកូនច្បងនៅក្នុង គ្រួសារដែលមានបងប្អូន ៤ នាក់ ស្រី ១ ប្រុស៣ ។ កាលពីកុមារភាព រហូតដល់មជ្ឈឹមវ័យ លោកជាកុមារា និង ជាយុវជនមួយរូបដែលរៀនសូត្រ បានគ្រាន់បើនឹងគេមួយរូប នៅក្នុង សាលា ថ្វីត្បិតតែមិនពូកែ តែក៏មិនជា អន់ពេកដែរ ។

លោកបានបន្តទៀតថា ស្ថានភាព ជីវិតរបស់លោក បានចាប់ផ្ដើមប្រែប្រួល ក្រោយពេលដែលលោក បាន មកភ្នំពេញបន្តការសិក្សានៅមហាវិទ្យាល័យនៅក្នុងទីក្រុងភ្នំពេញដោយ សារតែការសេពគប់មិត្តភ័ក្រ ។

លោក វាសនា បានបញ្ជាក់ថា " ដោយសារតែការសេពគប់នេះ ទើប ធ្វើឲ្យជីវិតខ្ញុំ បានត្រឹមតែជាកម្មករ ចល័ត និង អ្នករត់ម៉ូតូឌុប ដើម្បីចិញ្ចឹម ជីវិត ខណៈដែលប្អូនៗ គឺគេមាន ការងារ មានមុខរបររបស់គេត្រឹមត្រូវ ប្រសើរជាងខ្ញុំឆ្ងាយណាស់" ។

លោក វាសនា បានបន្តចែករំលែក បទពិសោធន៍ របស់លោកបន្តទៀត ថា ពេលមកដល់ភ្នំពេញ លោកចូល មហាវិទ្យាល័យបានត្រឹមតែមួយឆមាស ប៉ុណ្ណោះ ដោយសារតែស្គាល់មិត្តភ័ក្រ ជាកូនអ្នកធំ និងកូនអ្នកមាន ។

លោកបានបន្តទៀតថា ចាប់ពីពេល នោះមក លុយដែលឪពុកម្ដាយ បាន ផ្ញើពីស្រុក ថាជាលុយកាក់ចាយវាយ ប្រចាំថ្ងៃ និងលុយយកមកបង់សាលា រៀនគឺលោកបានចាយវាយខ្ចេចខ្ចីទៅ លើថ្លៃសំលៀកបំពាក់ ការដើរលេង ស៊ីផឹក និង ការប្រើប្រាស់ជីវិតដែល ហ៊ឺហារតាមមិត្តភ័ក្រ ប៉ុន្តែដល់ពេល ទទួលសញ្ញាប័ត្រគេមានលុយ គេមាន គ្នា មិត្តភ័ក្រគឺទទួលលាន់ លើកលែង តែរូបលោកដែលគ្មានឈ្មោះ ។

លោកបានបញ្ជាក់ថា "ខ្ញុំត្រូវគ្រួសារកាត់កាល់ ទើបជីវិតរស់នៅដូច សព្វថ្ងៃ"។

លោកបានបញ្ជាក់ថា "ខ្ញុំគិតខុស ដោយសារតែគិតថា ដើរជាមួយពួក គេ គឺមានបក្សពួក គ្រាន់គេជួយយក អាសារយើងនៅពេលខាងមុខ តែមាន អីពេលណាដែលយើង លែងមាន ប្រយោជន៍គេក៏លែងរាប់អាន "។

លោកបានបន្តទៀតថា នៅសម័យ ដើរលេងលោកប៊ិះនឹងជាប់ពន្ធនាគារ ផងដែរ ដោយសារតែការដើរលេងប៉ះ សំដី និង បង្កអំពើហិង្សានៅក្នុងក្រុម នោះហើយមួយយប់យកលុយបង់ថ្លៃ រៀនចាយអស់ក៏មានដែរ ខោអាវវិញ ទិញសុទ្ធតែអាវហាង មួយកំប្លេរថ្លៃ ដល់២០០ដុល្លារក៏មានដែរ តែឥឡូវ មានអីខោអាវ១០ដុល្លារថ្លៃហើយ។

លោក វាសនា បានបញ្ជាក់ថា "នេះជាបទពិសោធន៍ ហើយថ្ងៃមុខ បើខ្ញុំមានកូន ខ្ញុំនឹងប្រាប់ពួកគេឲ្យប្រយ័ត្ន អារឿងសេពគប់មិត្តភ័ក្រនេះសំខាន់ណាស់"។

លោក វាសនា បានឲ្យដឹងថា មក ដល់ពេលនេះលោកនៅមិនទាន់ហ៊ាន ចូលផ្ទះ ចូលថ្វាយបង្គំសុំខមាលទោស ពីឪពុកម្ដាយរបស់លោក នៅឡើយ ទេ ដោយខំប្រឹងរកស៊ី សន្សំលុយ ហើយបង្កើតមុខរបរអ្វីមួយ ឲ្យច្បាស់ លាស់ចាំចូលផ្ទះ។

លោកបានបន្តទៀតថា លុយលោក ទិញម៉ូតូនេះ គឺបានមកពីការសន្សំពី ការធ្វើកម្មករ ហើយបច្ចុប្បន្ន លោក បានសន្សំបានមួយចំនួនដែរ ហើយ កំពុងតែសម្លឹងមើល មុខរបរអ្វីមួយ ដែលប្រសើរជាងនេះបន្តិច ។

លោកអំ សំរិទ្ធ ជាអ្នកជាក់រ៉ឺម៉កដឹក ភេសជ្ជៈ លក់នៅក្នុងទីក្រុងភ្នំពេញ មួយរូបដែលកំពុងតែសំរាកនៅក្រោម ម្លប់អាគារនៅលើផ្លូវកែងនិងផ្លូវ២៧១ ក្បែរនោះ បានអះអាងថា ការសេពគប់ នេះសំខាន់ណាស់បើកាលណាយើង សេពគប់អ្នកដែលនាំយើងឲ្យចំរើនគឺ ចំរើនតាមគ្នាហើយ ប៉ុន្តែបើយើងទៅ សេពគប់ប៉ះអ្នកដែលមិនល្អជាពិសេស គឺក្រុមដែលអត់រៀន អត់ចូលសាលា វាសនាក៏ទៅតាមនោះដែរ។

លោក សំរិទ្ធ ក៏ជាមនុស្សមួយរូប ដែលមានអតីតភាពប្រហាក់ប្រហែល នឹងលោក វាសនា មួយរូបដែរ ។ លោកបានបន្តទៀតថា ជីវិតរបស់ លោកមានថ្ងៃនេះ ក៏ដោយសារតែការ សេពគប់នេះឯង កាលពីសម័យនៅ រៀន។

លោកបានបញ្ជាក់ថា "ខ្ញុំបោះបង់ សាលាតាំងពីថ្នាក់ទី៧ ដល់អត់ចំណេះ មានតែស្ម័គ្រចិត្តធ្វើទាហាន តែយើង អត់រៀនអត់ចំណេះ គឺបានត្រឹមតែ ពលទាហានហើយដល់គេកាត់រំសាយ ទៅ ក៏ចេះរកស៊ីតាមសម្មាអាជីវោ ដូច សព្វថ្ងៃនេះទៅ"។

លោកបានបន្តទៀតថា នៅសម័យ លោកអ្នកដែលស្ម័គ្រចិត្ត ធ្វើទាហាន ជាមួយគ្នា ដោយសារតែគេមានចំណេះ ខ្លះគេទៅរៀននៅរុស្ស៊ី ខ្លះទៅរៀននៅ វៀតណាម ប៊ុលហ្គារី អីមកវិញគេ ឡើងឧត្តមសេនីយអស់ហើយ តែខ្ញុំ បានត្រឹមតែប៉ុណ្ណឹង ។

លោកបានបញ្ជាក់ថា "នេះគឺជា បទពិសោធន៍ ឥចឹងហើយបានជាខ្ញុំ បានប្រាប់កូនថា បើចង់មានអនាគត ល្អ គឺខំរៀន តែបើចង់ដូចប៉ា គឺធ្វើ ឥចឹងទៀតទៅ "។

នេះគឺជាមេរៀនមួយ សម្រាប់យុវជន និងយុវនារីត្រិះរិះពិចារណាអំពី ការសេពគប់ ហើយក្រៅពីអ្នកទាំងពីរ នៅក្នុងសង្គមកម្ពុជា អ្នកដែលមាន ស្ថានភាពដូចពួកគាត់ គឺមានមិនតិច នោះទេ ៕

**ដោយ អរិយបុត្រ**

# ការថែទាំខ្លួនមុននិងក្រោយពេលអស់វដ្តរដូវ



អ្នកស្រី ហេង សុគន្ធមុន្នី ចៅនិងស្វាមី

*អ្វីទៅជាការអស់រដូវ?*

ការអស់រដូវ គឺជាការបញ្ចប់រដូវ បន្ទាប់ពីស្ត្រីមិនមានរដូវជាប់ៗគ្នារយៈពេល១ឆ្នាំឬបន្ទាប់ពីកាត់ខូចកន្សោមពង។ ភាគច្រើន ស្ត្រីអស់រដូវនៅចន្លោះពីអាយុ៤៥ដល់៥៥ឆ្នាំ។

ការប្រែប្រួល ក្រោយពេលអស់រដូវ៖

ស្បែកស្ងួតជ្រីវជ្រួញ ជ្រុះរោម ការថយចុះទំហំដោះ។ល។ ទាំងនេះជាសញ្ញាធម្មតា។

ការប្រឈមមុខក្រោយ ពេលអស់រដូវ៖

ស្ត្រីប្រឈមមុខនឹង ជំងឺពុកឆ្អឹង ជំងឺបេះដូង ជំងឺមហារីក ជាពិសេសមហារីកមាត់ស្បូន និងដោះ។ ដូច្នេះ ស្ត្រីគប្បីពិនិត្យសុខភាព ដោះ និង ស្បូន យ៉ាងយោចណាស់ឲ្យបានម្តងក្នុង១ឆ្នាំ។

វិធីថែទាំខ្លួននៅមុន និង ក្រោយអស់រដូវ៖

ស្ត្រីគ្រប់រូប មិនអាចជៀសផុត ពីការអស់រដូវបានទេដូច្នេះនាងត្រូវ៖

-ញ៉ាំអាហារដែល សំបូរជាតិកាល់ស្យូម និង វីតាមីនដេ(D) ដែលមាននៅក្នុងកំពិស ក្តាម ខ្យង ថ្លើមសត្វ។ល។ និងត្រូវញ៉ាំបន្លែ ផ្លែឈើឲ្យបានច្រើន។ បន្ថយអាហារមានជាតិខ្លាញ់ ស្ករ អំបិល។

-ធ្វើលំហាត់ប្រាណជាប្រចាំ ដូចជាដើរឲ្យបានច្រើន

-តាមដាន ការប្រែប្រួលទំងន់ខ្លួនជាប្រចាំ

-មិនត្រូវញ៉ាំស្រា ឬជក់បារីទេ

-ទៅពិគ្រោះជាមួយពេទ្យនៅពេលដែលមានរោគសញ្ញា ជិតអស់រដូវដើម្បីទទួលបានការថែទាំ និង វិធីព្យាបាលបង្ការ

-ធ្វើការពិនិត្យសុខភាពទូទៅ ជាពិសេស ដោះ និង ស្បូនយ៉ាងហោចណាស់ ក៏បានមួយដងក្នុង១ឆ្នាំ ទោះជាគ្មានរោគសញ្ញាអ្វីក៏ដោយ

-ប្រុងប្រយ័ត្ន ចំពោះរាល់ការប្រើប្រាស់ថ្នាំដែលរំខានដល់ការលូតលាស់នៃឆ្អឹង

-ពិភាក្សាជាមួយស្វាមី ដើម្បីពង្រឹងនិងបន្តសកម្មភាពផ្លូវភេទ។

( ដកស្រង់ ចេញពីសៀវភៅ ការស្វែងយល់ ពីបញ្ហាស្ត្រីនៅពេលអស់រដូវរបស់អង្គការរ៉ាក់)

# តំណាងសាសនារួមគ្នាចុះសួរសុខទុក្ខទណ្ឌិត



លោកអភិបាលចែកអំណោយទណ្ឌិតនៅខេត្តព្រះសីហនុ។

តំណាងសាសនា រួមមានព្រះសហគមន៍កាតូលិក និង ប្រូតេស្តង់ អ៊ីស្លាម និង ពុទ្ធបរិស័ទបានចុះសួរសុខទុក្ខ និងចែកអំណោយជូនដល់ទណ្ឌិតនៅពន្ធនាគារខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី២២ ខែធ្នូ កន្លងទៅ ដោយមានការរួម ពីលោកអភិបាល អូលីវីយេ ជ្មីតហាស្លែរ នៃភូមិភាគភ្នំពេញ ឯកឧត្តមប្លោក ផន រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា ឯកឧត្តមគង់ វិបុល អនុរដ្ឋលេខាធិការក្រសួងធម្មការ និង សាសនាលោកកង ឌីណា ប្រធានមន្ទីរធម្មការ និង សាសនាខេត្តព្រះសីហនុរួមទាំងព្រះសង្ឃ និង អស់លោក លោកស្រីជាប្រធានគ្រូគង្វាល អ៊ីម៉ាំ ហើយនិងបងប្អូនជាគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ ។

ថ្លែងនៅក្នុងឱកាសនោះ លោកអភិបាលអូលីវីយេ ជ្មីតហាស្លែរ មានប្រសាសន៍ថា នៅថ្ងៃនេះជាឱកាសមួយ និង ជាថ្មីម្តងទៀត យើងរួមគ្នាពីគ្រប់សាសនាទាំងអស់ ដែលមានតំណាងមកពី ខាងព្រះពុទ្ធសាសនា ឥស្លាមសាសនា ប្រូតេស្តង់ និង កាតូលិក បានខិតខំបង្ហាញធម៌មេត្តាករុណា បង្ហាញសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណា របស់ព្រះជាម្ចាស់ដល់បងប្អូនទាំងអស់ ។

ថ្លែងលើកទឹកចិត្តទៅកាន់បងប្អូនដែលកំពុងជាប់ឃុំឃាំង លោកអភិបាលមានប្រសាសន៍ថា នៅក្នុងជីវិតយើងពេលខ្លះ យើងមានភាពងងឹត ប៉ុន្តែនៅក្នុងភាពងងឹតនេះ យើងរកឃើញពន្លឺមួយ ដែលពន្លឺនេះណែនាំឲ្យយើងមានសេចក្តីសង្ឃឹម សម្រាប់ថ្ងៃអនាគត។ យើងដឹងហើយថា បងប្អូននៅទីនេះ បានរកឃើញពន្លឺមួយដែលនាំបងប្អូននឹកឃើញថា ក្នុងជីវិតរបស់ខ្លួនថា តើពន្លឺអ្វីខ្លះដែលណែនាំខ្ញុំ ដើម្បីឲ្យខ្ញុំកែប្រែចិត្តគំនិតកសាងខ្លួនទៅជាមនុស្សថ្មី មានកម្លាំងថ្មី នៅពេលដែលខ្ញុំចាកចេញពីទីនេះ ខ្ញុំមានសេចក្តីសង្ឃឹមថ្មី និងមានភាពក្លាហានដើម្បីកសាងជីវិតខ្ញុំ ឲ្យមានអនាគតសាជាថ្មីជាមួយក្រុមគ្រួសារខ្ញុំ និងក្នុងសង្គមកម្ពុជា។

ឯកឧត្តមប្លោក ផនរដ្ឋលេខាធិការក្រសួងធម្មការ និង សាសនាបានថ្លែងនៅក្នុងពិធីថា បងប្អូននៅទីនេះនាពេលកន្លងមក បងប្អូនមានការភ្លើតភ្លើន ហើយភ្លេចខ្លួនមួយភាំង នាំឲ្យបងប្អូនប្រព្រឹត្តិខុស នាំឲ្យបងប្អូនត្រូវជាប់ឃុំនៅទីនេះ ។ រយៈពេលកន្លងមក បងប្អូនបានធ្វើខុសជាមួយនឹងធម៌ព្រះផង និងខុសជាមួយនឹងច្បាប់របស់សង្គមផង ។ ប៉ុន្តែចាប់ពីពេលនេះតទៅ បងប្អូនខិតខំកែប្រែខ្លួន ដោយកសាងខ្លួនសារជាថ្មី ដើម្បីក្លាយជាមនុស្សល្អ។ នៅក្រោយពេលបងប្អូនចាកចេញពីទីនេះ បងប្អូនបានចូលរួមជួយកសាងសង្គមគ្រួសារខ្លួនផង និងជួយកសាងប្រទេសជាតិឲ្យបានរីកចម្រើនទៅថ្ងៃអនាគតផង។

គួរបញ្ជាក់ផងដែរថា អំណោយដែលចែកជូនទណ្ឌិត នាឱកាសនោះ មានម្ហូបអាហារ រួមនិងកញ្ចប់សម្ភារៈប្រើប្រាស់មួយចំនួន ។ ពន្ធនាគារខេត្តព្រះសីហនុ មានទណ្ឌិតចំនួន ៣៨៨នាក់ក្នុងនោះមានស្ត្រី២៧នាក់ រួមនិងកូនក្មេងនៅជាមួយម្តាយដែលជាប់ឃុំមួយចំនួនទៀត ៕

**ដោយ ឡុង សម្មស្ស**



# បច្ចេកវិទ្យាព័ត៌មានគឺជាទីផ្សារដ៏ទូលំទូលាយមួយនៅកម្ពុជា




លោក កេន ចាន់ថន ចូលរួមព្រឹត្តិការប្រជុំសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យា។

*បច្ចេកវិទ្យាព័ត៌មាន ត្រូវបានគេអះអាងថា គឺជាទីផ្សារដ៏ទូលំទូលាយ និង ជាកាលានុវត្តន៍ភាពមួយសម្រាប់កម្ពុជា ដូច្នេះដើម្បីឲ្យដឹងថា តើវិស័យនេះមានស្ថានភាពយ៉ាងណា និង មានកាលានុវត្តន៍ភាព យ៉ាងណា **អ្នកនាំសារ** សូមណែនាំមិត្តអ្នកអាន ឲ្យជួបជាមួយនឹង **លោក កេន ចាន់ ថន** ស្ថាបនិកក្រុមហ៊ុន កេនគ្រុប និង ជាអតីតប្រធានសមាគមសហគ្រិនវ័យក្មេងកម្ពុជា។*

*លោក ចាន់ថន ត្រូវបានគេដឹងថា គឺ ជាអតីតយុវជនកម្ពុជា មួយរូប ដែលមានប្រវត្តិ ចេញមកពីគ្រួសារបុគ្គលិក ចំការកៅស៊ូមួយកន្លែងនៅកម្ពុជា ប៉ុន្តែបានតស៊ូ និង ជំនះនូវឧបសគ្គជាច្រើន រហូតដល់លោកបានក្លាយជា អ្នកដឹកនាំក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មានមួយ ដែលហៅថា កេនគ្រុបនេះ កំពុងឈរជើងយ៉ាងរឹងមាំនៅកម្ពុជា។*

**អ្នកនាំសារ៖** តើក្រុមហ៊ុនលោកបង្កើតឡើងនៅពេលណា? ហេតុអ្វីបានជាលោក មានគំនិតបង្កើតជាក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មាននេះឡើង ?

**លោក កេន ចាន់ថន ៖** ក្រុមហ៊ុនខ្ញុំបានបង្កើតឡើង តាំងតែពីឆ្នាំ២០០៦ ។ ដោយសារតែខ្ញុំ មានប្រវត្តិការងារទាក់ទងនឹង វិស័យបច្ចេកវិទ្យាព័ត៌មាននេះ។ ខ្ញុំធ្លាប់ជាសមាជិកក្រុមការងារដែលចូលរួមរៀបចំប្រព័ន្ធ Software ឲ្យធនាគារ អេស៊ីលីដា កាលពីឆ្នាំ ២០០១ បន្ទាប់មក ខ្ញុំបានឃើញសក្តានុពលនៃវិស័យនេះ ហើយក៏បង្កើតក្រុមហ៊ុននេះតែម្តង ដោយចាប់ផ្តើមតំបូង មានបុគ្គលិក ៦ នាក់ ហើយបុគ្គលិករបស់ យើងកើនឡើងជារៀងរាល់ឆ្នាំ ប្រមាណជា ១៥ ភាគរយ។ មកដល់ពេលនេះ ក្រុមហ៊ុនរបស់យើង មាន៣ផ្នែកធំៗ គឺ ផ្នែក Software បន្ទាប់មកទៀតគឺ ផ្នែក សេវាកម្មបច្ចេកវិទ្យាព័ត៌មាននិង ផ្នែកទីបី គឺ មាតិកាឌីជីថល (Digital content)។ ហើយនៅពេលនេះ យើងកំពុងតែពង្រឹងខ្លួន ដើម្បីចាប់យកសេវាកម្មផ្សេងៗទៀត ដូចជា កម្មវិធីកំសាន្ត និង ផ្នែក E-commerce ជាដើម ។ល។

**អ្នកនាំសារ ៖** តើតាំងពីឆ្នាំ ២០០៦ មកដល់ពេលនេះ តើលោកប្រតិបត្តិការអាជីវកម្ម តែនៅក្នុងចង្កោមវិស័យផ្នែកបច្ចេកវិទ្យាព័ត៌មាន ឬ ក៏បានពង្រីកចូលទៅក្នុងវិស័យផ្សេង?

**លោក កេន ចាន់ថន ៖** ត្រង់ចំណុចនេះ ខ្ញុំសូមជំរាបថា តាំងពី២០០៦ មកដល់ ២០២០ គឺខ្ញុំមានគម្រោងត្រឹមតែផ្នែកបច្ចេកវិទ្យាព័ត៌មាន តែប៉ុណ្ណោះ។ ការអភិវឌ្ឍអាជីវកម្ម នៅក្នុងរង្វង់ផ្នែកបច្ចេកវិទ្យាព័ត៌មានគឺជាគោលដៅរបស់ខ្ញុំ ពីព្រោះថា នៅក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាននេះ គឺវាមាន ៧ ផ្នែកធំៗ ហើយមកដល់ពេលនេះ យើងមានតែ ៣ ដូច្នេះខ្ញុំចង់ពង្រីកថែមចំនួន ៤ ទៀត ដែលរួមមានដូចជា ទីមួយ ទូរគមនាគមន៍ ទីពីរ សេវាកម្មបណ្តុះបណ្តាល ទី៣ អ្នកចែកចាយផ្តាច់មុខ ផ្នែកសេវាកម្មបច្ចេកវិទ្យាព័ត៌មាន ទី ៤ គឺផ្នែកលក់រាយ ។

**អ្នកនាំសារ៖** តើទីផ្សារក្រុមហ៊ុនលោកមានស្ថានភាពយ៉ាងណាដែរ ?

**លោក កេន ចាន់ថន ៖** អតិថិជនរបស់ខ្ញុំ គឺ មានប្រមាណជា ៧០ ភាគរយ នៅក្រៅប្រទេស គឺ មាននៅកូរ៉េ និងអឺរ៉ុប ហើយថ្មីៗនេះយើងកំពុងតែជជែកគ្នាជាមួយនឹង អូស្ត្រាលី និង ញូវសេឡែន និង ជប៉ុន ។

**អ្នកនាំសារ ៖** តើលោកយល់យ៉ាងណាដែរអំពីវិស័យបច្ចេកវិទ្យាព័ត៌មានវិទ្យានាឆ្នាំ២០១៥ ពិសេស គឺក្រោយសមាហរណកម្មអាស៊ាន ?

**លោក កេន ចាន់ថន ៖** ពេលដែលយើងធ្វើសមាហរកម្មអាស៊ាន វិស័យព័ត៌មានវិទ្យា គឺជាវិស័យចាំបាច់បំផុតសម្រាប់ភ្ជាប់សេដ្ឋកិច្ច វប្បធម៌ នយោបាយ របស់ប្រទេសមួយៗ នៅក្នុងបណ្តាប្រទេសសហគមន៍អាស៊ាន ។ ឥឡូវនេះ យើងឃើញថា និន្នាការនៃវិស័យបច្ចេកវិទ្យាព័ត៌មាននេះ មានកំណើនជាប្រចាំ។ ទាំងការប្រើប្រាស់របស់ប្រជាពលរដ្ឋធម្មតា និង តាមក្រុមហ៊ុន ។ នៅក្នុងមួយឆ្នាំ វិស័យបច្ចេកវិទ្យាព័ត៌មាន នៅកម្ពុជាយើងបើព្យាកណ៍ទៅ គឺកើននៅក្នុងចន្លោះពី ៣០ ទៅ៤០ ភាគរយ។ ក្រៅពីតំរូវការនៅក្នុងសហគមន៍អាស៊ាន គឺ យើងអាចនឹងមាន កាលានុវត្តន៍ភាពមួយដែរ ទាក់ទងនឹងវិស័យការផ្តល់សេវាកម្មពីចំងាយ សម្រាប់ប្រទេសដែលខ្វះធនធានមនុស្ស លើជំនាញដែលមិន ទាមទារបច្ចេកទេសខ្ពស់ៗ ដូចជាផ្នែក Software development ផ្នែក IT Support ផ្នែករដ្ឋបាល ។ល។

**អ្នកនាំសារ ៖** តើក្រៅពីការផ្តល់សេវាកម្មពីចំងាយ តើទីផ្សារបច្ចេកវិទ្យាព័ត៌មាននៅកម្ពុជាបច្ចុប្បន្ននេះយ៉ាងណាដែរ ?

**លោក កេន ចាន់ថន ៖** ការផ្តល់សេវាកម្មពីចំងាយនេះគឺកម្ពុជាបានអនុវត្តផ្តល់សេវាកម្មនេះ តាំងតែពីឆ្នាំ២០០០តែយើង ខ្វះគោលនយោបាយលើកទឹកចិត្តលើវិស័យមួយនេះ ដែលនាំឲ្យកំណើននៅមានកំរិត។

**អ្នកនាំសារ ៖** តើបច្ចុប្បន្ននេះអ្នកដែលធ្វើសេវាកម្មពីចំងាយនេះ មានប៉ុន្មានក្រុមហ៊ុន ?

**លោក កេន ចាន់ថន ៖** ក្រុមហ៊ុនដែលល្បី ដែលកំពុងតែអនុវត្ត នៅលើវិស័យនេះគឺមានប្រមាណជាជាង៣០ ហើយ តែគាត់ធ្វើគឺនៅក្នុងលក្ខណៈស្ងាត់ស្ងៀម ដោយមានបុគ្គលិក ៣០ ទៅ៤០ នាក់ នៅក្នុងវីឡាមួយ ហើយជួនកាល មិនចុះបញ្ជីក្រុមហ៊ុនថែមទៀត ។

**អ្នកនាំសារ ៖** មកដល់ពេលនេះ តើកម្ពុជា មានក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មានប៉ុន្មានដែរ ?

**លោក កេន ចាន់ថន ៖** សម្រាប់ផ្នែកសេវាកម្ម គឺកម្ពុជាមានប្រមាណជាជាង ៣០០ ក្រុមហ៊ុន ដោយរាប់ទាំងកន្លែងលក់កុំព្យូទ័រ ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធើណែតជាដើមឡើង ។

**អ្នកនាំសារ ៖** តើស្ថានភាពទីផ្សារនៃវិស័យបច្ចេកព័ត៌មាននៅកម្ពុជា មានស្ថានភាពយ៉ាងណាដែរ?

**លោក កេន ចាន់ថន ៖** បើនិយាយអំពីកំណើន នៃវិស័យបច្ចេកវិទ្យាព័ត៌មាននេះ គឺយើងកើនឡើងពីមួយឆ្នាំ ៣០ ទៅ ៤០ ភាគរយ ប៉ុន្តែយើងនៅជាទីផ្សារមួយតូចនៅឡើយទេ តែអ្វីដែលយើងកត់សំគាល់ គឺអ្នកជំនាញការរបស់យើងមួយចំនួន គឺ បានចេញទៅធ្វើការ នៅបណ្តាប្រទេសផ្សេងៗបាន ដោយសារតែពួកគាត់មានសមត្ថភាព ហើយតម្លៃគាត់គួរសម ។

**អ្នកនាំសារ ៖** តាមប្រសាសន៍លោកលើកឡើងខាងលើ គឺរហូតមកដល់ពេលនេះមានក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មានជាច្រើន ដែលកំពុងដំណើរការដោយមិនចុះបញ្ជីត្រឹមត្រូវ តើប្រតិបត្តិការអាជីវកម្មបែបនេះ ល្អទេសម្រាប់ពួកគាត់ ?

**លោក កេន ចាន់ថន ៖** អ្វីដែលខ្ញុំនិយាយខាងលើ គឺ ថាក្រុមហ៊ុនដែលមិនសូវចុះបញ្ជី គឺក្រុមហ៊ុនដែលផ្តល់សេវាកម្ម ទៅខាងក្រៅ ប៉ុន្តែ បើផ្នែកផ្សេងៗ គឺភាគច្រើនចុះបញ្ជីត្រឹមត្រូវ។ នៅក្នុងផ្នែកបច្ចេកវិទ្យាព័ត៌មាន គឺវាមានបីផ្នែកធំៗ គឺមានដូចជា ១ គឺ ពិគ្រោះយោបល់ ទីពីរ ផ្នែក(System) និង ទីបី គឺ ផ្នែកសេវាកម្មពីចំងាយ។ នៅស្រុកខ្មែរយើងបច្ចុប្បន្ននេះ គឺដើរពីរ គឺ ផ្នែក System និង ផ្នែកសេវាកម្មពីចំងាយ។

**រូបភាពនិងអត្ថបទដោយ អរិយបុត្រ**

# រោងចក្រកាត់ដេរកម្ពុជានៅតែប្រឈមនឹងបញ្ហាពលកម្មកុមារ



កម្មករ-ការិនីរោងចក្រកាត់ដេរ ចេញពីរោងចក្រដើម្បីទទួលទានអាហារថ្ងៃត្រង់។ ដោយសហការី

វិស័យឧស្សាហកម្មកាត់ដេរ នៅក្នុងប្រទេសកម្ពុជាត្រូវបានគេអះអាងថាមានការរីកចម្រើន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏នៅតែប្រឈមមុខនឹងបញ្ហាមួយ គឺបញ្ហាពលកម្មកុមារ។

ឆ្លើយតប នឹងបញ្ហាប្រឈមនេះ កាលពីថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ២០១៤ អង្គការអន្តរជាតិខាងការងារ និង សមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយនៅក្នុងគោលបំណងលុបបំបាត់ពលកម្មកុមារ នៅក្នុងសួនឧស្សាហកម្មកាត់ដេរនៅកម្ពុជា ។

ពិធីចុះហត្ថលេខានេះ ត្រូវបានធ្វើឡើងដោយលោក វ៉ាន់ ស៊ូអៀង ប្រធានសមាគមរោងចក្រកាត់ដេរ នៅកម្ពុជា និង លោកស្រី ដាល តាក់គី ប្រធានគ្រប់គ្រងគម្រោង រោងចក្រកាន់តែប្រសើរនៅកម្ពុជា ក្រោមអធិបតីភាពរបស់លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ។

លោក អ៊ិត សំហេង បានមានប្រសាសន៍ថា ការលុបបំបាត់ពលកម្មកុមារប្រកបដោយសុវត្ថិភាព គឺជាគោលដៅមួយរបស់ដៃគូភាគី របស់គម្រោងរោងចក្រកាន់តែប្រសើរ នៅកម្ពុជា នៃអង្គការអន្តរជាតិខាងការងារដែលមានដូចជា រាជរដ្ឋាភិបាលកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និង សហជីព ។

លោកបានបន្តទៀតថា កិច្ចព្រមព្រៀងនេះគឺនឹងផ្តោតលើកិច្ចសហការរវាងសមាគមរោងចក្រកាត់ដេរ នៅកម្ពុជា និង គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាក្នុងដំណើរការស៊ើបអង្កេត និង ដោះស្រាយពលកម្មកុមារដែលបានរកឃើញ ។

លោករដ្ឋមន្ត្រីបានបន្តទៀតថានៅពេលកម្មករអាយុក្រោម ១៥ឆ្នាំ ត្រូវបានរកឃើញពួកគេនឹងត្រូវផ្តល់ដល់ស្ថាប័នបង្រៀន វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដ៏សមរម្យ និង ត្រូវបានផ្តល់ប្រាក់ខែប្រចាំខែជាមធ្យម ដែលរោងចក្រផ្តល់រហូតដល់ពួកគេ មានអាយុ ១៥ ឆ្នាំ។ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា នឹងជួយការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការស៊ើបអង្កេត និង ដំណោះស្រាយផ្សេងៗ នៃការចំណាយពីរោងចក្រដែលជាសមាជិក ។

តាមប្រសាសន៍ របស់លោករដ្ឋមន្ត្រី កាលពីពេលមុនមានការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រឆាំងទៅនឹងពលកម្មកុមារ រួមទាំងគោលដៅកាត់បន្ថយរូបភាព នៃពលកម្មកុមារ ក្នុងវិស័យទាំងអស់នៅទូទាំងប្រទេសពី ១៦,៥ ភាគរយ នៅក្នុងឆ្នាំ១៩៩៩ មកនៅត្រឹមតែ៨ ភាគរយ នៅក្នុងឆ្នាំ ២០១៥ ហើយនឹងលុបបំបាត់ទាំងស្រុង នៃទម្រង់ពលកម្មកុមារដ៏ធ្ងន់ធ្ងរបំផុត នៅត្រឹមឆ្នាំ ២០១៦។

លោករដ្ឋមន្ត្រីបានបញ្ជាក់ថា"នេះគឺជាការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលដើម្បីរួមគ្នាធានាថាឧស្សាហកម្មកាត់ដេរកម្ពុជាគ្មានពលកម្មកុមារ និង ដើម្បីការពារឈ្មោះ និង ម៉ាកសញ្ញារបស់កម្ពុជា ដែលបានដាក់ថា ផលិតនៅកម្ពុជា "។

ជុំវិញបញ្ហានេះ លោក វ៉ាន់ ស៊ូអៀង បានមានប្រសាសន៍ថា គ្មានពលកម្មកុមារ គឺជាគោលការណ៍កម្រិតសូន្យរបស់សមាគមរោងចក្រកាត់ដេរ នៅកម្ពុជា ។

លោកបានបន្តទៀតថា ដើម្បីដោះស្រាយ និង លុបបំបាត់បញ្ហាដ៏អសកម្មទាំងនេះពីរោងចក្រកាត់ដេរ នៅកម្ពុជា យើងកំពុងតែធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា។

លោកបានបន្តទៀតថា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានសហការជាមួយនឹងគម្រោងនេះ និង អង្គការអន្តរជាតិខាងការងារអស់រយៈពេលជាង ១៤ ឆ្នាំមកហើយ។

លោកបានបន្តទៀតថា ការចុះកិច្ចព្រមព្រៀងនេះ គឺជាជំហានមួយថ្មីដែលនឹងនាំឲ្យការប្តេជ្ញាចិត្តរបស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និង អ្នកដែលពាក់ព័ន្ធ ចំពោះដំណោះស្រាយវិជ្ជមានមួយសម្រាប់កម្មករនិយោជិតមិនទាន់គ្រប់អាយុ ដែលចូលបំរើការមិនត្រឹមត្រូវ។

សម្រាប់កិច្ចព្រមព្រៀងនេះ លោកស្រី ដាល តាក់គី ប្រធានគ្រប់គ្រងគម្រោងរោងចក្រកាន់តែប្រសើរ នៅកម្ពុជាបានមានប្រសាសន៍ថា ទាក់ទងនឹងពលកម្មកុមារ នៅតាមរោងចក្រកាត់ដេរនៅកម្ពុជា គឺនៅតែមានតែលទ្ធផល នៃការត្រួតពិនិត្យ គឺឃើញថា មានការធ្លាក់ចុះជាលំដាប់។

លោកស្រីបានបញ្ជាក់ថា "ការឃ្លាំមើលរបស់គម្រោង នៃរោងចក្រកាន់តែប្រសើរនៅកម្ពុជា បានសម្គាល់ពីការធ្លាក់ចុះ នៃសំណុំរឿងពលកម្មកុមារដែលរកឃើញក្នុងឆ្នាំ ២០១៤ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៣" ។

កញ្ញា រិន ចរិយា ជាកម្មការិនីវ័យ ១៩ ឆ្នាំមួយរូបបានអះអាងថា កញ្ញាបានក្លាយជា កម្មការិនីរោងចក្រកាត់ដេរនៅក្នុងរាជធានីភ្នំពេញនេះ ប្រមាណជាជាង៥ ឆ្នាំ។

កញ្ញាបានបញ្ជាក់ថា "ខ្ញុំមកធ្វើការនៅភ្នំពេញនេះ ជាមួយនឹងបងស្រីៗនៅក្នុងភូមិតាំង ពីអាយុប្រហែលជា ១៤ឆ្នាំ ដោយប្រាប់គេថា ខ្ញុំមានអាយុ ១៦ ឆ្នាំ"។

កញ្ញា បានបន្តទៀតថា ដោយសារតែកញ្ញា ជាមនុស្សត្រឡោក ធាប់ធំខាងរដ្ឋបាលរោងចក្រ គេមើលទៅទំនងក៏ឲ្យចូលទៅ ហើយក៏បានបំរើការជាបន្តបន្ទាប់មកដល់សព្វថ្ងៃនេះ ។

កញ្ញា បានបន្តទៀតថា តាមបទពិសោធន៍នៅក្នុងការធ្វើ កម្មការិនីរោងចក្រកាត់ដេរ ៣ ទៅ ៤ ឆ្នាំកន្លងមក គឺថា អ្នកដែលមានស្ថានភាពដូចនាងគឺមានច្រើន ដោយអ្នកខ្លះគេលួចកែថ្ងៃខែឆ្នាំកំណើត ។

រហូតមកដល់ពេលនេះគេដឹងថា ឧស្សាហកម្មកាត់ដេរនៅកម្ពុជាគឺជាដង្ហើមសេដ្ឋកិច្ចមួយដ៏ចំបង របស់ប្រទេស។ វិស័យនេះ ត្រូវបានគេដឹងថា គឺជាប្រភពនាំចេញប្រមាណជា ៨០ ភាគរយនៃ ផលិតផលនាំចេញសរុបរបស់ប្រទេស។ ទីផ្សារ នៃផលិតផលនាំចេញរបស់ផលិតផល នៃឧស្សាហកម្មកាត់ដេរ នៅកម្ពុជា មានដូចជា អឺរ៉ុប អាមេរិក ...។ល។

**ដោយ អរិយបុត្រ**

# ព័ត៌មានទូទៅ

## ជនបរទេស៦សញ្ជាតិកំពុងកាន់កាប់ការងារបច្ចេកទេសសំខាន់ៗនៅកម្ពុជា

តួរលេខបានបង្ហាញថា មកដល់ពេលនេះប្រទេសកម្ពុជា ក៏ជាទីផ្សារការងារមួយ របស់ជនបរទេសមួយចំនួនផងដែរ។

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថាពលករបរទេស ដែលកំពុងតែបំរើការនៅកម្ពុជា គឺ មានទាំងអស់ ១៦.៩០០ នាក់ នៅក្នុងនោះ គឺមាន ៦ សញ្ជាតិធំៗ គឺ មាន ចិន វៀតណាម ហ្វីលីពិន ថៃ កូរ៉េខាងត្បូង និង ម៉ាឡេស៊ី ។

ប្រភពដដែលឲ្យដឹងថា សម្រាប់ជនជាតិចិនត្រូវបានគេដឹងថា គឺកំពុងតែកាន់កាប់ការងារផ្នែក បច្ចេកទេស ឬ ជាមេការ វៀតណាមជាកម្មករនិងជាអ្នកបច្ចេកទេសខ្លះ ហ្វីលីពិនគ្រូភាសារ សេវាកម្មកំសាន្ត និង ទីផ្សារសម្រាប់ថៃ និងម៉ាឡេស៊ី គឺអ្នកជំនាញផ្នែកឧស្សាហកម្មទេសចរណ៍ កូរ៉េខាងត្បូងជាអ្នកជំនាញការបច្ចេកទេស ។

ចំនួនជនបរទេសដែលមកបំរើការនៅកម្ពុជា គឺមានការកើនឡើងទ្វេរដងបើធៀបនឹងឆ្នាំ ២០១៣កន្លងទៅ ។ ដែលមានដូចជា ជនជាតិចិន មានចំនួន ៨.៤៥៣នាក់, វៀតណាម ២.១៣៣នាក់, ហ្វីលីពីន ១.២៦១ នាក់ ថៃ៩៥៣នាក់, កូរ៉េខាងត្បូង ៧៦១នាក់និងម៉ាឡេស៊ី៦៦៨នាក់៕

## វិបត្តិនៅរុស្ស៊ីកំពុងបង្កផលប៉ះពាល់វិស័យទេសចរណ៍នៅក្នុងតំបន់

វិបត្តិសេដ្ឋកិច្ច ដែលកំពុងតែកើតមាននៅក្នុងប្រទេសរុស្ស៊ី បណ្តាលមកពីការធ្លាក់ចុះនៃលុយ "រូប" ក្រោយពេលដែលសហគមន៍អឺរ៉ុប បានដាក់ទណ្ឌកម្មសេដ្ឋកិច្ច ទៅលើប្រទេសរុស្ស៊ី បានបង្កជាផលប៉ះពាល់ដល់ការរំពឹងទុកនៃកំណើនភ្ញៀវទេសចរចូលមកតំបន់ជាពិសេស គឺ វៀតណាម និងថៃ។

លុយរូបរបស់រុស្ស៊ីនៅពេលថ្មីៗនេះ បានដាំក្បាលចុះជាបន្តបន្ទាប់បើធៀបនឹងប្រាក់ដុល្លារ ក្រោយពេលដែលរុស្ស៊ី ត្រូវរងនូវទណ្ឌកម្មសេដ្ឋកិច្ច ពីសហគមន៍អឺរ៉ុប និង អាម៉េរិក ហើយជាពិសេសគឺវិបត្តិ នៃការធ្លាក់ចុះតម្លៃប្រេងកាតឆៅ នៅលើទីផ្សារអន្តរជាតិ ។

នៅក្នុងចំណោមប្រទេស នៅក្នុងតំបន់ ប្រទេសវៀតណាម ប្រហែលជាប្រទេសដែលរងនូវផលប៉ះពាល់លើវិស័យទេសចរណ៍ពីរុស្ស៊ី ច្រើនជាងគេ ដោយសារតែភ្ញៀវទេសចរពីរុស្ស៊ី គឺជាទីផ្សារដ៏ចម្បងរបស់វៀតណាម ក្រោយពេលដែលប៉ះទង្គិច ជាមួយនឹងចិនរឿងដែនអធិបតេយ្យនៅសមុទ្រចិនខាងត្បូង ។

លោក ឃ្វៀន វ៉ានថាន់ អនុប្រធានគណៈកម្មការ សមាគមទេសចរណ៍ ខាញ់ ហាវ បានអះអាងថា វិបត្តិនយោបាយនេះ មិនប៉ះពាល់ដល់វិស័យ ទេសចរណ៍ខេត្តនេះនៅក្នុងឆ្នាំនេះទេ តែឆ្នាំ២០១៥ គឺប្រាកដ។

លោកបានអះអាងថា ចន្លោះពីខែវិច្ឆិកា និង មេសា គឺជាខែដែលភ្ញៀវទេសចររុស្ស៊ី មិនសូវមកទេសចរណ៍វៀតណាមទេ ដូច្នេះឆ្នាំនេះ មិនមានផលប៉ះពាល់ធ្ងន់ធ្ងរ តែឆ្នាំក្រោយ គឺអាចធ្ងន់ធ្ងរ។ លោក ឃ្វៀន ដុកថាន នាយកចាត់ការ ក្រុមហ៊ុនទេសចរណ៍ អាណិច ទួហ៍ បានអះអាងប្រាប់បណ្តាញព័ត៌មានវៀតណាមថា នៅខែធ្នូនេះ ការកក់របស់ភ្ញៀវទេសចររុស្ស៊ីប្រចាំថ្ងៃបានថយចុះពីជាង២០០ នាក់ នៅក្នុងមួយថ្ងៃមកនៅត្រឹមតែ ពី ៧០ ទៅ ៨០ នាក់ តែប៉ុណ្ណោះ ពោលគឺថយចុះប្រមាណជា៦០ ភាគរយ។

លោកបានបន្តទៀតថា ឆ្នាំនេះក្រុមហ៊ុនបានផ្តល់សេវាកម្មដល់ភ្ញៀវទេសចររុស្ស៊ី បានចំនួន ១២០.០០០ នាក់ ពោលគឺកើនឡើង ៤ដង ធៀបនឹងឆ្នាំ២០១៣ កន្លងទៅ ប៉ុន្តែឆ្នាំនេះគឺពិតជាយ៉ាប់ ។

នៅពេលដែល មិនទាន់មានវិបត្តិ ភ្ញៀវទេសចររុស្ស៊ី គឺចំណាយ ៨០០ ដុល្លារសម្រាប់សម្រាកនៅសណ្ឋាគារផ្កាយ៤នៅវៀតណាម ដោយការចំណាយនេះ គឺស្មើនឹង២៨.០០០ រូប ប៉ុន្តែឥឡូវនេះ គឺពួកគេត្រូវចំណាយរហូតដល់ទៅ៤៩.០០០ រូប៕

## កម្ពុជាមានអ្នកជំងឺឆ្កួតជ្រូក៨៦.០០០នាក់

ការស្ទាបស្ទង់មតិមួយ ដែលធ្វើឡើងអំពីជំងឺឆ្កួតជ្រូកនៅកម្ពុជា គេរកឃើញថា កម្ពុជាមានអ្នករងគ្រោះដោយជំងឺនេះប្រមាណជា៨៦.០០០ នាក់។ នេះបើតាមប្រសាសន៍របស់លោក ច័ន្ទ សំឡេង ប្រធានសមាគមគ្រូពេទ្យប្រសាទសាស្ត្រកម្ពុជា និងជាអនុប្រធានសមាគមកម្ពុជាប្រឆាំងជំងឺឆ្កួតជ្រូក។

លោកវេជ្ជបណ្ឌិត បានមានប្រសាសន៍នៅក្នុងសិក្ខាសាលា ស្តីអំពីជំងឺនេះ និង ការមានផ្ទៃពោះ ដែលរៀបចំកាលពីពេលថ្មីៗនេះថា នៅក្នុងចំណោមអ្នកជំងឺទាំងនោះ គឺមានប្រមាណជា៦៦ភាគរយ នៅមិនទាន់បានទទួលការព្យាបាលត្រឹមត្រូវ ឬមិនបានទទួលការព្យាបាលតែម្តង។

លោកវេជ្ជបណ្ឌិត បានឲ្យដឹងថា ជំងឺឆ្កួតជ្រូក គឺជាជំងឺមួយដែលមានការប៉ះពាល់ទៅលើកោសិការបស់ប្រព័ន្ធប្រសាទ ហើយនៅពេលមានការប៉ះពាល់ វាបណ្តាលឲ្យបន្ទុកអគ្គិសនីនៅក្នុងកោសិកាខួរក្បាលមានការកើនឡើង និង ត្រូវបញ្ចេញបន្ទុកអគ្គិសនីនោះចេញមកក្រៅ ដែលធ្វើឲ្យអ្នកជំងឺលេចចេញនូវរោគសញ្ញាមួយចំនួនផ្សេងៗពីគ្នា ប៉ុន្តែជាទូទៅអ្នកជំងឺឆ្កួតជ្រូកមានរោគសញ្ញា ដូចជា ប្រកាច់បែកពពុះមាត់ ហើយអ្នកខ្លះអាចសន្លប់ជាដើម។

លោកវេជ្ជបណ្ឌិត បានឲ្យដឹងថា ដើម្បីឲ្យដឹងច្បាស់ ត្រូវប្រញាប់ទៅជួបជាមួយគ្រូពេទ្យជំនាញ ដើម្បីទទួលសេវាប្រឹក្សាពិនិត្យរកជំងឺនេះ ចៀសវាងការធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯង។

លោកបានបន្តថា ជំងឺឆ្កួតជ្រូក អាចព្យាបាលបាន ហើយការព្យាបាលគឺប្រើឱសថ ដែលអាចប្រឆាំងនឹងជំងឺឆ្កួតជ្រូក និង ជម្រើសនៃការរស់នៅដ៏ល្អប្រសើរ ៕

## បណ្ឌិត យ៉ង់ សាំងកុមារ

### ប្រតិកម្ម នឹងរបាយការណ៍រឿងប្រព័ន្ធស្រោចស្រពនៅកម្ពុជា

លោក បណ្ឌិត យ៉ង់ សាំងកុមារ ប្រធានមជ្ឈមណ្ឌលសិក្សា និង អភិវឌ្ឍកសិកម្មកម្ពុជា ដែលពលរដ្ឋទូទៅស្គាល់ថា អង្គការ សេដាក បានបង្ហាញនូវប្រតិកម្មដ៏ខ្លីលាយឡំនឹងសំនួរចំពោះរបាយការណ៍អំពីប្រព័ន្ធស្រោចស្រពនៅកម្ពុជា។

លោកបានប្រតិកម្ម នៅក្នុងទំព័របណ្តាញព័ត៌មានសង្គមរបស់លោក កាលពីចុងខែធ្នូ ឆ្នាំ២០១៤ទៅនឹងសេចក្តីរាយការណ៍មួយ ដែលថាប្រព័ន្ធធារាសាស្ត្រដែលប្រទេសកម្ពុជាមានពេលនេះមានលទ្ធភាពស្រោចស្រពលើផ្ទៃដីស្រែបានដល់ចំនួនប្រមាណជា ៦១,០៤ ភាគរយនៃផ្ទៃដីសរុប។

ជុំវិញ សេចក្តីរាយការណ៍នេះ លោកបានបញ្ជាក់ថា "វាអាចពិតជាមានដល់៦០ភាគរយ តែដំណើរការស្រោចស្រព បានពេញលេញបានប្រហែលជាង១០ភាគរយ នៃផ្ទៃដីសរុបទេ"។

តាមសេចក្តីរាយការណ៍ របស់ក្រសួងធនធានទឹក និង ឧតុនិយម បានឲ្យដឹងថា ប្រព័ន្ធធារាសាស្ត្រដែលបានស្តារឡើងវិញ និងកសាងថ្មីនៅទូទាំងប្រទេស មកទល់នឹងដំណាច់ឆ្នាំ ២០១៤ មានលទ្ធភាពស្រោចស្រពលើផ្ទៃដីស្រែបានចំនួនប្រមាណ ១.៥៥៧.០៣៨ ហិកតា ស្មើនឹង ៦១,០៤ ភាគរយ នៃផ្ទៃដីសរុប ២.៥៥០.៨០៩ ហិកតា។

ប្រភពដដែល បានបន្តទៀតថា ប្រព័ន្ធធារាសាស្ត្រ ដែលកម្ពុជាមានត្រឹមដំណាច់ឆ្នាំ២០១៤នេះ មាន លទ្ធភាពទឹកសម្រាប់ផ្គត់ផ្គង់ផ្ទៃដីស្រូវប្រាំង បានរហូតដល់ប្រមាណជា ៥០ ម៉ឺនហិកតា៕

# ឆ្នាំ២០១៤ កម្ពុជាចាប់ផ្តើមដោយប្រទាំងប្រទើស តែឆ្នាំ២០១៥ពលរដ្ឋសុំ

ពលរដ្ឋស៊ីវិល នៅក្នុងប្រទេសកម្ពុជា បានស្នើសុំឲ្យឆ្នាំថ្មី ២០១៥ នេះឆ្លងផុតដោយរលូន កុំឲ្យមានព្រឹត្តិការណ៍បង្ហូរឈាមគ្នា កើតមានឡើងដូចជាឆ្នាំចាស់២០១៤ ថែមទៀត។

លោក សាញ់ សំណប់ ជាប្រជាពលរដ្ឋវ័យ ៦២ ឆ្នាំ មួយរូបបានអះអាងថា កាលពីឆ្នាំចាស់ យើងឆ្លងឆ្នាំដោយវិបត្តិនយោបាយ ហើយឆ្លងភ្លាមគឺអំពើហិង្សានយោបាយផ្ទុះឡើងភ្លាម តែឆ្នាំនេះ តាមព័ត៌មានគឺដូចជាមិនអីទោះបីជា សភាពការនយោបាយហាក់មានការប្រែប្រួលខ្លះៗ នៅដើមឆ្នាំ ២០១៥ នេះ ។

លោក សំណប់ បានមានប្រសាសន៍ នៅកន្លែងតៀមការហ្វេមួយនាផ្សារគគី តាមផ្លូវជាតិលេខ១បញ្ជាក់ថា "តាមដែលខ្ញុំចាំ កាលពីឆ្នាំចាស់ឆ្នាំ២០១៤ បើកឆាកភ្លាម គឺមានព្រឹត្តិការណ៍បង្ហូរឈាម នៅផ្លូវវេងស្រេងភ្លាម តែឆ្នាំនេះ តាមវិទ្យុ គឺដូចជាមិនអី ហើយលិចឮថា ព្រះអង្គក្រុមព្រះលោក យាងមកដឹកនាំគណបក្សហ៊្វុនស៊ីនប៉ិចវិញតែប៉ុណ្ណោះ" ។

លោក ដុះ ចំណាប់ ជាអ្នករត់ម៉ូតូកង់បីមួយរូបដែលកំពុងតែឈប់រង់ចាំម៉ូយនៅលើផ្លូវវេងស្រេងនេះ បានអះអាងបញ្ជាក់ការចងចាំព្រឹត្តិការណ៍កាលពីដើមឆ្នាំ ២០១៤កន្លងទៅថា "ខែនេះឆ្នាំទៅ នៅកន្លែងនេះ ខ្ញុំបើកម៉ូតូគេចជុំថ្ម និង គ្រាប់កាំភ្លើងទាំងព្រលឹងចុងសក់ តែឥឡូវដូចជាធម្មតា តែគ្រាន់តែបរិស្ថានផ្លូវនេះ គឺស្អុយបន្តិច ដោយសារតែអត់លូ មនុស្សវាច្រើន"។

គួររំលឹកដែរថា កាលពីឆ្នាំ ២០១៤ កន្លងទៅ ជាពិសេសនៅក្នុងរយៈពេលដើមឆ្នាំ ជាដំណាក់កាលដែលសភាពការណ៍នយោបាយនៅកម្ពុជា ស្ថិតនៅក្នុងភាពពុះកញ្ជ្រោលខ្លាំង ដោយប្រទេស គឺរងនូវការធ្វើបាតុកម្មរបស់គណបក្សសង្គ្រោះជាតិដែលបដិសេធមិនចូលសភា ដែលអូសបន្លាយចាប់តាំងពីក្រោយការប្រកាសលទ្ធផលនៃការ បោះឆ្នោតខែ កក្កដា ឆ្នាំ២០១៣ នៅទីលានប្រជាធិបតេយ្យ និង មហាបាតុកម្មទាមទារ តម្លើងប្រាក់ខែកម្មករ បូករួមទាំងបញ្ហាផ្សេងៗ នៅក្នុងសង្គម ដូចជាវិបត្តិដីធ្លី ការទាមទារតម្លើងប្រាក់ខែរបស់គ្រូបង្រៀន នៅកន្លែងសាធារណៈផ្សេងៗ បានធ្វើឲ្យបាតុកម្មនេះឈានដល់ដំណាក់កាលទំនោរវិវត្តន៍ទៅជាអំពើបាតុកម្មហិង្សានៅលើផ្លូវវេងស្រេង ដែលនាំឲ្យអាជ្ញាធរបង្ក្រាបរហូតដល់បាត់បង់ជីវិត ៤នាក់ ១០នាក់របួស និង ២០ នាក់ ត្រូវបានចាប់ខ្លួន នាថ្ងៃទី០៣ ខែមករា ឆ្នាំ ២០១៤ ហើយបាតុកម្មនោះ បាននាំដល់ការបំផ្លាញទ្រព្យសម្បត្តិ ប្រជាពលរដ្ឋ ក្រុមហ៊ុនឯកជន និង សាធារណៈ ជាច្រើនលានដុល្លារ ។

បន្ទាប់ពីអំពើហិង្សាបានផ្ទុះនៅផ្លូវវេងស្រេងនៅថ្ងៃទី០៤ ខែមករា ឆ្នាំ ២០១៤ អាជ្ញាធរមានសមត្ថកិច្ច បានបើកការបង្ក្រាបបាតុកម្មទាំងអស់នៅក្នុងរាជធានីភ្នំពេញ ដោយរួមទាំងទីលានប្រជាធិបតេយ្យ ហើយបានហ៊ុំព័ទ្ធ និង ដាក់កំលាំងមានសមត្ថកិច្ចការពារនៅទីនោះ រួចប្រកាសបទបញ្ជាហាមការប្រមូលផ្តុំ។

ការប្រកាសយកទីលានប្រជាធិបតេយ្យ និង សិទ្ធិសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋជាចំណាប់ខ្មាំងរបស់រាជរដ្ឋាភិបាល ដែលកាន់កាប់ដោយគណបក្សកាន់អំណាច និង គណបក្សប្រឆាំង បានបន្តអូសបន្លាយរហូតដល់ថ្ងៃទី ១៥ ខែ កក្កដា ក៏ផ្ទុះចេញ នូវអំពើហិង្សាមួយថ្មីទៀតរវាងបាតុករ ដែលដឹកនាំដោយគណបក្ស



ប៉ូលីសកំពុងសែងបាតុករបឹងកក់តវ៉ាអំពីដីធ្លីនិងផ្ទះរបស់ពួកគាត់។ ដោយ ណារ៉ុង

## សម្តេចក្រុមព្រះ ប្រកាសយាងមកដឹកនាំ គណបក្សហ៊្វុនស៊ិនប៉ិច

សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ដែលបានចាកចេញពីគណបក្សហ៊្វុនស៊ិនប៉ិច តាំងពីឆ្នាំ២០០៦ បានប្រកាសកាលពីដើមឆ្នាំ២០១៥ ថា ព្រះអង្គយល់ព្រមវិលត្រឡប់ និងយាងមកដឹកនាំគណបក្សរាជានិយមមួយនេះជាថ្មីម្តងទៀត ។

សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ដែលបច្ចុប្បន្នកំពុងគ្រប់គ្រងគណបក្សមួយដែលមានឈ្មោះថា គណបក្សសង្គមរាស្ត្ររាជាធិបតេយ្យនោះ បានយល់ព្រម យាងទៅធ្វើជាប្រធានគណបក្សហ៊្វុនស៊ិនប៉ិចវិញហើយ តាមសំណើរបស់សម្តេចព្រះរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច និងលោក ញឹក ប៊ុនឆៃ អគ្គលេខាធិការបក្ស។

នៅពេលដែលបានសំរេចចិត្តយាងត្រឡប់ ទៅដឹកនាំគណបក្សនេះវិញ សម្តេចក្រុមព្រះបានមានបន្ទូលថា គណបក្សហ៊ុនស៊ិនប៉ិច នឹងគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សកាន់អំណាច គឺជាជន្ទល់ដ៏រឹងមាំសម្រាប់ការពាររបបរាជានិយមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ព្រះអង្គបានប្រកាសថា ការវិលត្រឡប់របស់ព្រះអង្គមកក្នុងគណបក្សនេះ នឹងអាចជួយឲ្យគណបក្សនេះ អាចទទួលបានសម្លេងនៃការគាំទ្រពីប្រជាពលរដ្ឋកម្ពុជាឡើងវិញ នៅក្នុងការបោះឆ្នោត នាឆ្នាំ២០១៨ ខាងមុខនេះ ហើយព្រះអង្គនឹងរៀបចំនូវរចនាសម្ព័ន្ធគណបក្សឡើងវិញ ជាពិសេសគឺថ្នាក់មូលដ្ឋាន ដើម្បីបង្រួបបង្រួមអ្នករាជានិយម និង អ្នកសីហនុនិយម ។

សម្តេចក្រុមព្រះ ព្រះអង្គបានចាកចេញពីឆាកនយោបាយមួយរយៈកាលពី ឆ្នាំ២០១០ ហើយចូលមកវិញរួចក៏ប្រកាសចាកចេញម្តងទៀតនៅឆ្នាំ២០១២ ប៉ុន្តែ បានប្រកាសចូលឆាកនយោបាយវិញ កាលពីខែមីនា ឆ្នាំ២០១៤ ។

សម្តេចក្រុមព្រះ ត្រូវបានគេដឹងថាគឺជាអតីតសហនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ពីឆ្នាំ១៩៩៣ ដល់ ១៩៩៧ ហើយក៏ធ្លាប់ធ្វើជាប្រធានរដ្ឋសភាផងដែរ។

# កុំឲ្យមានអ្វីកើតឡើងដូចឆ្នាំចាស់ថែមទៀត



ប្រឆាំង និង ប្រជាពលរដ្ឋរហូតដល់បង្ករបួសស្នាម ដល់កងសន្តិសុខ ៣០រូប និង បាតុករ ១០រូប នៅពេលដែលបាតុករព្យាយាម ចូលទៅរំដោះទីលានប្រជាធិបតេយ្យ ហើយកងសន្តិសុខ ព្យាយាមការពារតាមបទបញ្ជា ។ ព្រឹត្តិការណ៍នេះបាននាំដល់ការឃាត់ខ្លួនតំណាងរាស្ត្រជាប់ឆ្នោតគណបក្សប្រឆាំងចំនួន ៧ រូប ។

៧ ថ្ងៃក្រោយ មកសភាពការណ៍ក្តៅគគុក ដែលបានផ្ទុះតាំងពីខែមករា ដល់ខែកក្កដា គឺបានធូរស្រាលក្រោយជំនួបចរចារ រវាងមេដឹកនាំគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិពោលគឺជំនួបកំពូលរវាងសម្តេចតេជោ ហ៊ុន សែន អនុប្រធានគណបក្សប្រជាជនកម្ពុជា និង លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិហើយក៏បានចេញនូវកិច្ចព្រមព្រៀងនយោបាយរួមគ្នាមួយដែលមាន ៧ប្រការ បញ្ចប់វិបត្តិនយោបាយ ដោយនៅក្នុងប្រកាទាំងនោះគឺ ផ្តោតសំខាន់ ទៅលើកំណែទម្រង់ ការបោះឆ្នោតរៀបចំក្បាលម៉ាស៊ីន ដឹកនាំសភាជាថ្មី ពោលគឺបានព្រមព្រៀងបង្កើតគណកម្មការទី ១០ មានឈ្មោះថាគណកម្មការអង្កេតបោសសំអាតនិងប្រឆាំងអំពើពុករលួយ ។

សភាពការណ៍នយោបាយ នៅកម្ពុជា រិតតែធូរស្រាលទៅទៀតនោះគឺថា តំណាងរាស្ត្រគណបក្សប្រឆាំងទាំង ៥៥ រូប របស់គណបក្សប្រឆាំងដោយរួមទាំង៧រូបដែលត្រូវបានចាប់ខ្លួន បានចូលស្បថយកអភ័យឯកសិទ្ធិ នាថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៤ ហើយថ្ងៃទី ០៨ ខែដដែល បានចូលប្រជុំសភា រួមជាមួយនឹងគណបក្សប្រជាជនកម្ពុជា ដែលគ្រប់គ្រងអសនៈភាគច្រើននៅក្នុងសភាជាលើកដំបូង ។

សព្វថ្ងៃនេះ រដ្ឋសភាត្រូវបានគេអះអាងថា គឺមានតុល្យភាពនៃអំណាចស្របតាមអសនៈដែលគណបក្សទាំងពីរបានដណ្តើមបានការគាំទ្រពីម្ចាស់ឆ្នោត ដោយរដ្ឋសភា បានធ្វើការកែទម្រង់លើក្បាលម៉ាស៊ីនដឹកនាំ នៃស្ថាប័ននិតិបញ្ញត្តិ ពោលគឺទាំងរដ្ឋសភា និង ព្រឹទ្ធិសភា ដោយឡែកកំណែទម្រង់គណកម្មាធិការ ជាតិរៀបចំការបោះឆ្នោតគឺកំពុងតែដំណើរការពិភាក្សា ដោយក្រុមការងារជំនាញគណបក្សទាំងពីរ ។

ក្រោយមកទៀតនៅក្នុងថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៤អនុប្រធានគណបក្សប្រជាជនកម្ពុជា និង ប្រធានគណបក្សសង្គ្រោះជាតិ បានជួបប្រជុំគ្នា ដែលក្រោយពីកិច្ចប្រជុំ គឺ គណបក្សទាំងពីរ បានឯកភាពឲ្យគណបក្សសង្គ្រោះជាតិ បង្កើតស្ថានីយទូរទស្សន៍ និងការដាក់ឲ្យដំណើរការនូវស្ថានីយវិទ្យុ ហើយក៏បានឯកភាពគ្នាធ្វើវិសោធនកម្ម បទបញ្ញាផ្ទៃក្នុងរដ្ឋសភា ដើម្បីរៀបចំឲ្យគណបក្សសង្គ្រោះជាតិ មានប្រធានក្រុមតំណាងរាស្ត្រភាគតិចនៅសភា ដើម្បីជាគូសន្ទនាជាមួយនឹង ប្រមុខរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងបញ្ហារបស់ជាតិ ដោយប្រធានក្រុមនោះ គឺមានឋានៈស្មើនឹងនាយករដ្ឋមន្ត្រី។

ទាក់ទងនឹង កំណែទម្រង់គណកម្មាធិការ ជាតិរៀបចំការបោះឆ្នោតក្រុមការងារ ជំនាញរបស់គណបក្សទាំងពីរ បានឈានដល់ចំណុចសញ្ញាតិរបស់សមាជិក គ.ជ.ប ដោយសមាជិកទាំង៩គឺ មិនត្រូវជាប់សាច់ញាតិនឹងថ្នាក់ដឹកនាំគណបក្សនយោបាយណាមួយ មានសញ្ជាតិតែមួយ គឺ ខ្មែរ នៅក្នុងពេលបំរើការនៅ គ.ជ.ប ។នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំដដែលរដ្ឋសភាបានប្រជុំអនុម័តជាឯកច្ឆ័ន្ទលើសេចក្តីស្នើវិសោធនកម្មបទបញ្ញាផ្ទៃក្នុងរដ្ឋសភា ដែលនាំដល់ការ បើកផ្លូវការបង្កើតប្រធានក្រុមមតិភាគតិចនៅរដ្ឋសភា ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នៅចុងឆ្នាំ២០១៤ គឺ មានផ្ទុះរឿងពុករលួយ នៅក្នុងគណបក្សសង្គ្រោះជាតិលើថវិការ ប្រមាណជា ២០ លានដុល្លារ ។

លោក ជុន សុបញ្ញា អាជីវករមួយរូបបានឲ្យដឹងថា សភាពការនយោបាយកម្ពុជា នៅក្នុងឆ្នាំនេះ វាដូចជារដូវភ្លៀង ដែលមានព្យុះមានរន្ទះមានភ្លៀងធ្លាក់ទឹកជំនន់ប៉ុន្តែនៅពេលនេះពពកខ្មៅនៃនយោបាយ ពោលគឺព្យុះភ្លៀង និង រន្ទះនយោបាយរសាយអស់ហើយ ។

លោកបានបន្តទៀតថា ស្តាប់សភាពការណ៍តាមវិទ្យុ អានកាសែតអី បញ្ហាវានៅមាន តែមិនជាធុំដុំទេ ហើយខ្ញុំក៏មិនភ័យព្រួយអីទៀតដែរ ។ លោកបានបញ្ជាក់ថា "ខ្ញុំសង្ឃឹមថាស្រុកយើងនឹងសុខស្រួល បន្តទៀតកុំដូចជា សភាពការណ៍នៅស្រុកគេដូចជាអេស៊ីបនៅស៊ីរីអី"។

លោកបានបន្តទៀតថា ប្រទេសកម្ពុជា ទំរាំបានសមិទ្ធិផលត្រឹមប៉ុណ្ណេះ មិនមែនជារឿងដែលចំណាយពេលតិចនោះទេ គឺ៣៦ ឆ្នាំ ដូច្នេះការធ្វើនយោបាយឈ្លោះគ្នាអី ឈ្លោះតែមាត់ទៅកុំនាំរាស្ត្រទៅរកអំពើហិង្សា និង បំផ្លិចបំផ្លាញ៕

## សន្តិភាពគឺជាឫសគល់នៃការអភិវឌ្ឍ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានមានប្រសាសន៍ថា ឫសគល់នៃសន្តិភាព និង ការអភិវឌ្ឍនៅក្នុងប្រទេសនាពេលសព្វថ្ងៃនេះ គឺដោយសារតែទឹកចិត្តបង្រួបបង្រួមជាតិរបស់ប្រជាពលរដ្ឋកម្ពុជាទាំងមូល ។

សម្តេចតេជោ បានមានប្រសាសន៍នៅក្នុងពិធីសម្ពោធ ស្ថានីយវារីអគ្គិសនីឫស្សីជ្រុំក្រោម ក្នុងខេត្តកោះកុង កាលពីថ្ងៃទី១២ ខែមករា បានថ្លែងអំណរគុណ ចំពោះប្រជាពលរដ្ឋកម្ពុជា គ្រប់និន្នាការនយោបាយដែលមានទឹកចិត្តបង្រួបបង្រួមធ្វើឱ្យប្រទេសជាតិមានសន្តិភាព និង ធ្វើការអភិវឌ្ឍបាននោះ។

សម្តេចតេជោបញ្ជាក់ថា "នេះជាសមិទ្ធផលសន្តិភាពសម្រាប់ប្រទេសយើង ដែលខ្ញុំសូមថ្លែងអំណរគុណជាមួយ នឹងទឹកចិត្តបង្រួបបង្រួមនៃប្រជាពលរដ្ឋកម្ពុជា និងគ្រប់ភាគីពាក់ព័ន្ធដែលអនុញ្ញាតឱ្យប្រទេសរបស់យើងអាចបង្រួបបង្រួមបាន និង មានសន្តិភាពពេញលេញហើយផ្តល់ឱកាសឲ្យយើងអាចអភិវឌ្ឍបាននៅថ្ងៃនេះ។

សម្តេចតេជោថ្លែងថា យើងត្រូវដឹងថា នេះហើយជាសមិទ្ធផលនៃសន្តិភាពសម្រាប់ប្រទេស បើសភាពការណ៍ដូចមុនឆ្នាំ១៩៩៨ នៅតំបន់នេះកុំនិយាយឡើយពីគម្រោងនេះ សូម្បីតែគិតក៏គិតមិនចេញផង។

សម្តេចតេជោបានមានប្រសាសន៍បន្តទៀតថា សមិទ្ធផលសន្តិភាពនេះ ផ្តល់ឱកាសឱ្យយើងមានលទ្ធភាព ដើម្បីបានមកអភិវឌ្ឍដូចជាវារីអគ្គិសនី ។ បើសិនជាពុំមានសន្តិភាព បង្កើតឡើងតាមរយៈនយោបាយឈ្នះ ឈ្នះ ទេ យើងកុំនិយាយដល់ការអភិវឌ្ឍកុំនិយាយដល់ការកសាងសមិទ្ធផល ។

# តំណាងអន្តរសាសនាជួបជុំគ្នា ចុះសួរសុខទុក្ខ និងចែកអំណោយដល់ទណ្ឌិតនៅកំពត

ក្នុងឱកាសបុណ្យ អបអរសាទរព្រះយេស៊ូប្រសូត្រ តំណាងអន្តរសាសនា ដែលមានគ្រីស្តសាសនានិកាយកាតូលិក និង ប្រូតេស្តង់ អ៊ីស្លាមសាសនានិងព្រះពុទ្ធសាសនា រួមនឹងមន្ត្រីរាជការ យ៉ាងច្រើនកុះករ បាននាំគ្នាចុះសួរសុខទុក្ខដល់ទណ្ឌិតក្នុងពន្ធនាគារខេត្តកំពត ព្រមទាំងជូនអំណោយបន្តិចបន្តួចផងដែរ និងបានជួបជុំគ្នា ធ្វើការសំណេះសំណាលរវាងសាសនា និង សាសនាកាលពីព្រឹកថ្ងៃទី០៦ ខែមករា កន្លងទៅ។

លោកអភិបាល អូលីវីយេ ដ្មីត ហាស្លេរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានលើកទឹកចិត្តដល់ទណ្ឌិតទាំងនោះឲ្យខិតខំសម្លឹងទៅមុខ និងចេះរៀបចំអនាគតរបស់ខ្លួនដោយមានសង្ឃឹម។ លោកពោលថា " ចូរបងប្អូនរៀបចំជីវិត ដើម្បីឲ្យមានសេរីភាពក្នុងដួងចិត្ត ពោលគឺបងប្អូននៅតែជាមនុស្ស ដែលមានតម្លៃថ្លៃថ្នូរដូចគេដែរ"។

ក្នុងនោះដែរ តំណាងនៃសាសនាព្រះពុទ្ធ និង អ៊ីស្លាម ក៏បានផ្តល់ជាដំបូន្មានដល់ទណ្ឌិតទាំងអស់ ឲ្យខិតខំកែប្រែចិត្តគំនិត និង របៀបនៃការរស់នៅថ្មី ដោយមិនប្រព្រឹត្តកិច្ចការដែលមានទោសទណ្ឌបន្តទៀតក្រោយពេលមានសិទ្ធិសេរីភាពឡើងវិញ។

ក្រោយពីផ្តល់ឱវាទ នៃតំណាងសាសនានីមួយៗ ក្នុងពិធីនោះដែរ ក៏មានការអធិដ្ឋានសូត្រធម៌ រួមជាមួយទណ្ឌិតផងដែរ ។ ចំពោះអំណោយដែលចែកជូនបងប្អូននៅក្នុងពន្ធនាគារនាឱកាសនោះរួមមានម្ហូបអាហារ និង កញ្ចប់ សម្ភារៈប្រើប្រាស់មួយចំនួនសម្រាប់បងប្អូនដែលជាប់ឃុំ សរុបចំនួន ៣៦៣នាក់ ក្នុងនោះមានស្ត្រីចំនួន២១នាក់។ បន្ទាប់មក តំណាងសាសនាទាំងអស់ក៏បានមកជួបជុំគ្នានៅព្រះសហគមន៍កំពត ដើម្បីសំណេះសំណាល និង ស្គាល់គ្នាទៅវិញទៅមក។ បន្ទាប់ពីការចែកអំណោយទណ្ឌិត គណៈប្រតិភូទាំងអស់ បានបន្តជួបជុំគ្នា នៅមណ្ឌលសកម្មភាពកំពត។

លោកអភិបាលអូលីវីយេ មានប្រសាសន៍ថា នៅក្នុងពិភពលោកយើងសព្វថ្ងៃនេះ គឺឆ្នាំ ២០១៤កន្លងទៅ ពិភពលោករបស់យើង មានសង្គ្រាមជាច្រើន នៅតាមបណ្តាប្រទេសមួយចំនួនក្នុងអាស៊ី ក៏ដូចមជ្ឈឹមបូព៌ា ពិសេសប្រទេសរបស់ព្រះយេស៊ូ គឺប្រទេស អ៊ីស្រាអែល កំពុងកើតមានសង្គ្រាមនៅពេលសព្វថ្ងៃនេះ។ ការចេះតែស្អប់គ្នា ឈ្លោះគ្នា សម្លាប់គ្នា ណែនាំឲ្យយើងមើលឃើញថា ពិភពលោកទាំងមូល និងមិនមានសន្តិសុខនោះឡើយ ។ ដូច្នេះមានតែការសន្ទនាគ្នាដើម្បីស្គាល់គ្នា និងយោគយល់គ្នាទេទើបយើងអាចរស់នៅក្នុងសង្គមមួយដ៏សុខសាន្តបាន។

លោកអភិបាល ក៏បានសំណូមពរផងដែរថា សូមឲ្យមេដឹកនាំគ្រប់សាសនាទាំងអស់ ជួយជំរុញឲ្យយុវជនយុវនារី ដែលកំពុងរស់នៅក្នុងសង្គមរីកចម្រើនលឿនឲ្យកសាងជីវិត ឈរលើគ្រឹះនៃគុណធម៌ សីលធម៌ យ៉ាងច្បាស់លាស់។ការជួបជុំគ្នានៅថ្ងៃនេះ គឺជាឧទាហរណ៍មួយ ក្នុងការជួយដល់យុវជនឲ្យរិះគិតអំពីសាសនាមានន័យថា ប្រសិនបើអត់មានសាសនា អត់មានអនាគតសម្រាប់ពិភពលោកទាំងមូល ។

ព្រះតេជគុណ ធាន ផន ព្រះចៅអធិការវត្តព្រៃតុម តំណាងខាងព្រះពុទ្ធសាសនាមានសង្ឃដីកាថា ការជួបជុំសន្ទនាគ្នានាថ្ងៃនេះ គឺជាការកសាងទំនាក់ទំនងល្អរវាងសាសនាមួយ ទៅសាសនាមួយ ។ សូមឲ្យអ្នកកាន់សាសនាទាំងអស់ ប្រកាន់នូវចិត្តសណ្តោសចំពោះគ្នា និង គ្នាគ្រប់សាសនាទាំងអស់ ត្រូវមានកិច្ចសហការគ្នា ដើម្បីការអភិវឌ្ឍ លើវិស័យសាសនា ។

លោក លី សារី ជាប្រធានគណៈឥស្លាមប្រចាំខេត្តកំពត បានមានប្រសាសន៍ថា "ការប្រាស្រ័យទាក់ទងគ្នានាំឲ្យមានការស្គាល់គ្នា អស់មន្ទិលសង្ស័យនិងគ្នា ពោលគឺមិនមានទំនាស់គ្នារវាងសាសនាមួយ និង សាសនាមួយ ។ យើងជាខ្មែរដូចគ្នា ប៉ុន្តែយើងត្រូវរស់ជាមួយគ្នា បើទោះជាយើងកាន់សាសនាផ្សេងៗគ្នា ក៏ដោយ យើងចូលរួមជាមួយគ្នា ដើម្បីកិច្ចការអភិវឌ្ឍ" ។

កម្មវិធីជួបជុំអន្តរសាសនានេះត្រូវបានព្រះសហគមន៍កាតូលិក កំពត រៀបចំឡើងជារៀងរាល់ឆ្នាំ តាំងពីឆ្នាំ ២០០៦មក ក្នុងគោលដៅសំណេះសំណាលគ្នា រវាងសាសនាធំៗ៣នៅក្នុងប្រទេសកម្ពុជាស្គាល់គ្នា និងដើម្បីធ្វើសកម្មភាពមនុស្សធម៌រួមគ្នាមួយចំពោះទណ្ឌិត។

**ដោយឡុង សម្ផស្ស**

# គ្រីស្តបរិស័ទរំលែកថវិកា ដើម្បីរៀបចំបុណ្យព្រះយេស៊ូប្រសូត



គ្រីស្តបរិស័ទកំពុងធ្វើម្ហូបសម្រាប់ពិធីបុណ្យព្រះយេស៊ូប្រសូត។

នៅព្រះសហគមន៍ ត្រែងត្រយឹង ស្ថិតក្នុងខេត្តកំពង់ស្ពឺ។ គ្រីស្តបរិស័ទទាំងអស់ បានប្រមូលថវិកាផ្ទាល់ខ្លួនដើម្បីរៀបចំ កម្មវិធីបុណ្យព្រះយេស៊ូប្រសូត ដែលបានរៀបចំឡើង កាលពីថ្ងៃទី២៨ ធ្នូកន្លងទៅ។

លោក ឡេង ហុង ជាប្រធានគណៈកម្មការព្រះសហគមន៍ នៅទីនោះបានឲ្យដឹងថា មិនត្រឹមតែថវិកាប៉ុណ្ណោះទេ ដែលបងប្អូនបានផ្តល់ឲ្យ គឺពួកគាត់បានមកជួយជាកំលាំងផងដែរ ទាំងការសម្តែងរឿងតុបតែងឆាក របាំ ពិធីបុណ្យ និងអាហារហូបជាដើម។

លោកព្រំ ង៉ោ អាយុ៧២ឆ្នាំ ជាសមាជិក នៃគណៈកម្មការព្រះសហគមន៍ត្រែងត្រយឹង បានឲ្យដឹងថា៖ បុណ្យឆ្នាំនេះ ពិតជាមានភាពសប្បាយរីករាយជាងរាល់ឆ្នាំ ព្រោះបានឃើញគ្រីស្តបរិស័ទ និងយុវជនទាំងអស់ចេះរួបរួមគ្នា ធ្វើឲ្យកម្មវិធីនេះអធិកអធម និង បានធ្វើឲ្យអ្នកភូមិជិតខាង មានចំណាប់អារម្មណ៍ក្នុងការទស្សនា រឿងព្រះយេស៊ូប្រសូត្រ ជាពិសេសគឺរបាំផងដែរ។ លោកបន្តថា៖ ព្រះយេស៊ូប្រសូត្រ គឺនាំសេចក្តីសុខសាន្តដល់មនុស្សទាំងអស់ ដូចនេះយើងត្រូវយកព្រះយេស៊ូជាគំរូ និងបង្កើតសេចក្តីសុខសាន្ត និងសន្តិភាពក្នុងភូមិរបស់យើង។

លោកអ៊ុនសុនជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពព្រះសហគមន៍ក្រុងព្រះសីហនុ បានមានប្រសាសន៍ក្នុងធម្មទេសនាថា "សូមឲ្យព្រះយេស៊ូប្រសូត្រ ក្នុងដួងចិត្តរបស់យើង និងយើងចេញទៅប្រកាសអំពីធម៌មេត្តាករុណា របស់ព្រះជាម្ចាស់ ដោយបើកដួងចិត្ត ហើយកែប្រែចិត្តគំនិតសារជាថ្មី ដោយចេះស្រឡាញ់អ្នកដទៃ និង ចេះជួយគ្នាទៅវិញទៅមក"។ លោកបូជាចារ្យបន្តថា ក្នុងឆ្នាំនៃការសម្តែងធម៌មេត្តាករុណានេះ សូមឲ្យយើងបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកដទៃ និងស្របពេលព្រះយេស៊ូប្រសូត្រនេះផងដែរ។

ក្នុងពិធីបុណ្យ ព្រះយេស៊ូប្រសូតនេះ គ្រីស្តបរិស័ទនៃព្រះសហគមន៍ត្រែងត្រយឹង ក្នុងខេត្តកំពង់ស្ពឺ បានរួមកម្លាំងគ្នា និងប្រមូលថវិកាបានចំនួន៤០៨ដុល្លារអាមេរិកដើម្បីរៀបចំបុណ្យព្រះយេស៊ូប្រសូត ដែលមានអ្នកចូលរួមប្រមាណជា៤០០នាក់៕

# អ្នកចូលរួមប្រកួតខ្លែងឯកលើកទី៤មានចំនួនច្រើនជាងរាល់ឆ្នាំ

ការប្រកួតខ្លែងឯក ហាក់ដូចជា មានប្រជាប្រិយភាពបន្តិចម្តងៗ ពី មួយឆ្នាំទៅមួយឆ្នាំចំពោះប្រជាជនក្នុង ស្រុកត្រាំកក់ខេត្តតាកែវ។ នេះបើ តាមការឲ្យដឹង របស់គណៈកម្មាការ រៀបចំការប្រកួត។

លោកមាគ ស៊ន បានឲ្យដឹងថា ឆ្នាំ នេះ មានអ្នកប្រកួតរហូតដល់១២៧ ក្រុម។ ឆ្នាំទៅមានតែ៩០ប៉ុណ្ណោះ។

លោកបានឲ្យដឹងទៀតថា ទិសដៅ សំខាន់ នៃការរៀបចំកម្មវិធី បង្ហោះ ខ្លែងឯកនេះ គឺព្រះសហគមន៍កាតូលិកចង់ឲ្យប្រជាជនក្នុងតំបន់ អាច ចូលរួម និង ស្គាល់ព្រះសហគមន៍ កាតូលិក ហើយព្រះសហគមន៍ក៏អាច ស្គាល់ពីវប្បធម៌ខ្មែរដែរ ជាពិសេស នេះជាកីឡាមួយប្រភេទ ដែលនាំឲ្យ មានអំណរសប្បាយ ជាពិសេសក្នុង ឱកាសបុណ្យ ព្រះយេស៊ូប្រសូត ។ ហើយយើង អាចលេងបានទាំងក្មេង ទាំងចាស់មិនតែប៉ុណ្ណោះ ព្រះសង្ឃក៏ អាចលេងបានដែរ។

តាមឯកសារមួយចំនួន បានឲ្យ ដឹងថា ខ្លែងឯក ធ្វើឡើងពីឧបករណ៍ ភ្លេងមួយប្រភេទ ដែលបន្លឺបានច្រើន សម្លេងយ៉ាងពីរោះ នៅពេលហោះ ឡើងលើអាកាស។ ការបង្ហោះខ្លែង ឯកកម្សាន្តសប្បាយ គឺជាការបង្ហោះ ជាសហគមន៍។

ដៃកាន់ខ្លែងប្រកបដោយទឹកមុខរំភើបនិងសប្បាយផង យុវសិស្ស លី ពិសិដ្ឋ អាយុ ១៧ឆ្នាំ ជាម្ចាស់ជ័យ លាភីលេខ១ ប្រចាំឆ្នាំ២០១៤ នៃ ស្រុកត្រាំកក់ បានឲ្យដឹងថា "ខ្ញុំរំភើប ស្ទើរតែមិនអាចនិយាយបាន ព្រោះ នេះជាលើកទីមួយនៅក្នុងជីវិត ដែល បានទទួលរង្វាន់បែបនេះ ហើយនេះ ក៏ជាលើកទីមួយ នៃការដាក់ពាក្យ ប្រកួតនេះដែរ។" ពិសិដ្ឋបន្តថា ជ័យ លាភីនេះ គឺបានមកពីការខិតខំយក ចិត្តទុកដាក់ខ្ពស់ទាំងបច្ចេកទេស នៃ ការបង្ហោះ និង របៀបធ្វើខ្លែងដោយ គិតប៉ាន់ប្រមាណទៅលើផ្នឹងខ្លែងនិង ទំហំខ្យល់។ ពិសិដ្ឋបន្ថែមថា ថវិកា ដែលបានឈ្នះនេះ នឹងយកទៅប្រើ ប្រាស់ក្នុងការសិក្សា និងតាមតំរូវការ គ្រួសារ។

ក្នុងការប្រកួតនេះ អ្នកទទួលបាន ជ័យលាភីលេខ១ ទទួលបានប្រាក់ រង្វាន់ចំនួនម្ភៃពីរម៉ឺនរៀល លេខ២ ដប់ប្រាំបួនម៉ឺនរៀល លេខ៣ដប់ប្រាំ មួយម៉ឺនរៀល លេខ៤ដប់បីម៉ឺនរៀល និង លេខ៥ ទទួលបានដប់មួយម៉ឺន រៀល។ រីឯកីឡាករ ដែលមិនជាប់ ចំណាត់ថ្នាក់ខាងលើ ទទួលបាន ប្រាក់លើកទឹកចិត្ត១ក្រុមពីរម៉ឺនរៀល ផងដែរ។

នេះជាការប្រកួតលើកទី៤ បាន ធ្វើឡើងកាលពីថ្ងៃទី ២៧ ធ្នូ ដែល មានការអញ្ជើញចូលរួម ពីតំណាង មន្ទីរធម្មការ និង សាសនា ព្រះសង្ឃ មន្ត្រីរាជការ និងលោកអភិបាល អូលីវីយេ ឆ្មឹតហស្លេរនៃភូមិភាគភ្នំពេញ។



អ្នកប្រកួតខ្លែងកំពុងត្រៀមខ្លួនដើម្បីបង្ហោះខ្លែង។ ដោយ សុធីរិទ្ធ

លោកអភិបាល អូលីវីយេ បាន មានប្រសាសន៍ថា ថ្ងៃនេះជាឱកាស មួយដែលបង្ហាញថា យើងជាក្រុម គ្រួសារមួយ ទោះបីយើងមកពីភូមិ ផ្សេងៗក៏ដោយ ហើយសង្ឃឹមថាយើង នឹងមានមនុស្សច្រើនទៅៗ ជារៀង រាល់ឆ្នាំ។ ថ្ងៃនេះក៏សូមអរគុណដល់ ចៅអធិការវត្តតំណាងក្រសួងធម្មការ ដែលបានចូលរួមជាមួយគ្នា ដែលជា លក្ខណៈអន្តរសាសនាគឺទាំងព្រះពុទ្ធ សាសនា និង គ្រីស្តសាសនា ដែល បង្ហាញថា យើងរួមគ្នាថែរក្សាវប្បធម៌ និង មានអំណរសប្បាយជាមួយគ្នា។

លោកគាំ ដាំផេង អនុប្រធានមន្ទីរ ធម្មការ និង សាសនាខេត្តតាកែវ បានមានប្រសាសន៍ថា ការប្រកួត តែងតែមានចាញ់ និង ឈ្នះតែសូម ប្រយ័ត្ន និង រៀបលក្ខណៈឲ្យបាន ត្រឹមត្រូវដើម្បីប្រកួត។ លោកបន្តថា ខ្លែងឯកមាន ២៧ប្រភេទ តែយើង យកតែមួយប្រភេទមកប្រឡង ។ លោកក៏បានលើក ពីប្រវត្តិនៃការប្រកួតខ្លែងនេះថា កាលពីមុនគេប្រកួត មួយឆ្នាំ២ដង គឺដើមឆ្នាំ និងចុងឆ្នាំ នៅពេលដែលគេ ប្រមូលផលស្រូវ រួច។ លោកផេងបានថ្លែងអំណរគុណ ដល់លោកអភិបាល ដែលជាបុគ្គល ឆ្នើមមួយរូបដែលតែងយកចិត្តទុកដាក់ ជួយដល់ផ្នែកសាសនានិង សង្គម។

ការប្រកួតបង្ហោះខ្លែងនេះ ព្រះ សហគមន៍បានរៀបចំឡើង ក្នុងឆ្នាំ ២០១១នារដូវរំហើយ។ លោកលីឡាយស្រេង អតីតឧបនាយករដ្ឋមន្ត្រី បានឧបត្ថម្ភចំនួន៥០ ដុល្លារអាមេរិក សាលាបឋមសិក្សាវត្តអង្គមន្ត្រី២១ម៉ឺនរៀល គណៈកម្មការវត្តអង្គមន្ត្រី១១ ម៉ឺនរៀល និង មានប្រជាពលរដ្ឋមួយ ចំនួន បានចូលរួមឧបត្ថម្ភក្នុងការ ប្រកួតនេះដែរ៕

**ដោយ ដាលីស**

# សន្ត កាមីល



សន្ត កាមីល កើតនៅប្រទេសអ៊ីតាលី នៅឆ្នាំ១៥៥០ ឪពុកគាត់ ឈ្មោះ យ៉ូហាន ជាទាហានម្នាក់។ ថ្ងៃមួយ ម្តាយរបស់គាត់សុបិនឃើញ កាមីល កំពុងណែនាំយុវជនជាច្រើន ដែលស្លៀកពាក់អាវធំ និង មានឈើឆ្កាងនៅខាងមុខ។ ម្តាយរបស់គាត់ ខិតខំបង្រៀនគាត់ ឲ្យចេះស្រឡាញ់ អ្នកក្រីក្រ និង អធិដ្ឋាន តែគាត់មិន រវល់ទាល់តែសោះ រហូតដល់ម្តាយ គាត់ស្លាប់ ឪពុកក៏បានយកកូនប្រុស ទៅរស់នៅជំរំទាហាន ហើយបង្រៀន កូនឲ្យក្លាយជាទាហាន។ តែកាមីល មិនលះបង់ ចោលទំលាប់អាក្រក់ របស់ខ្លួនឡើយ គាត់ចូលចិត្តលេង បៀរផឹកស្រា និង វាយតប់គ្នា បើទោះ បីគាត់បានបាត់បង់អ្នកមានគុណទាំង ពីរក៏ដោយ។ ពេលនៅសមរភូមិគាត់ មានរបួសជើងក៏បានទៅសម្រាកនៅ មន្ទីរពេទ្យសន្តយ៉ាកុប។ ការព្យាបាល នោះត្រូវចំណាយពេលយូរដូច្នេះគាត់ គ្មានប្រាក់បង់ថ្លៃព្យាបាល ក៏ធ្វើការនៅ ទីនោះជំនួសវិញ។ តែមិនបានប៉ុន្មាន ផងគាត់ក៏ត្រូវបានគេបញ្ឈប់ឲ្យធ្វើការ ព្រោះតែទំលាប់ និង ចរិកមិនល្អរបស់ គាត់។ លុះក្លាយជាជនអនាថារសាត់ អណ្តែតគ្មានគោលដៅ កាមីលក៏បាន ទៅគោះទ្វារវិហារមួយ និង សូមឲ្យ លោកបូជាចារ្យជួយគាត់។ ពេលនោះ កាមីល បានធ្វើការផ្នែកសំណង់ សម្រាប់ក្រុមបព្វជិត ដែលមានឈ្មោះ ថា "កាពូសាំង"។ បន្ទាប់មក កាមីល បានជួប និង លោកបូជាចារ្យ អាង គេលូ អ្នកទាំងពីរបាននិយាយគ្នា យ៉ាងយូរ ហើយលោកបូជាចារ្យក៏បាន ណែនាំកាមីលឲ្យកែប្រែចិត្តគំនិត ផង ដែរ។ លុះកាមីលត្រឡប់វិញបានរិះ គិតពីពាក្យរបស់ លោកបូជាចារ្យ ហើយលុតជង្គង់ចុះយំ។ រួចលោក សម្រេចចិត្តធ្វើជាបព្វជិត។ កាមីល ប្រែចិត្តគំនិតយ៉ាង ពិតប្រាកដមែន គាត់ធ្លាប់និយាយថា ៖ " អ្នកជំងឺជា ព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ដូច្នេះ អ្វី ដែលយើងធ្វើសម្រាប់គេ ក៏ដូចជា យើងធ្វើសម្រាប់ព្រះជាម្ចាស់ដែរ " ។ លោកត្រូវបានតែងតាំងជា បូជាចារ្យ នៅអាយុ ៣៤ឆ្នាំ ហើយលោកបាន បង្កើតក្រុមគ្រួសារបព្វជិត មានឈ្មោះ ថា "ក្រុមនៃអ្នកបម្រើរបស់អ្នកជំងឺ"។ សុបិនម្តាយគាត់ បានលេចឡើងជា រូបរាងហើយ៕

# ក្រុមសិស្សពិការ មណ្ឌលអារ៉ូពេ ចូលរួមរត់ម៉ារ៉ាតុន



សិស្សពិការមណ្ឌលអារ៉ូពេចូលរួមរត់ម៉ារ៉ាតុន។ ឡុង សម្មស្ស

ដើម្បីចូលរួម ផ្សព្វផ្សាយអំពីការយល់ដឹង និងបំបាត់គ្រាប់មីននៅក្នុងប្រទេសកម្ពុជា ក្រុមសិស្សពិការ នៃមណ្ឌលអារ៉ូពេចំនួន ៥០នាក់ បានចូលរួមរត់ម៉ារ៉ាតុន នៅខេត្តសៀមរាប កាលពីថ្ងៃទី០៧ ខែធ្នូ កន្លងទៅនេះ ដោយមានការជួយឧបត្ថម្ភ ពីអង្គការ និងដៃគូផ្តល់មូលនិធិ មកមណ្ឌលអារ៉ូពេ នៃព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង។

លោក ឡូរ៉េនហ្សូ ហ្សាវ៉ាឡា (Lorenzo Zavala) ជាអ្នកស្ម័គ្រចិត្តជួយព្រះសហគមន៍កាតូលិក បាត់ដំបងក្នុងមណ្ឌលអារ៉ូពេ បានឲ្យដឹងថា នេះជាលើកទីពីរហើយ ដែលក្រុមសិស្សនៃមណ្ឌលអារ៉ូពេ ចូលរួមក្នុងកម្មវិធីរត់ម៉ារ៉ាតុន នៅខេត្តសៀមរាបនាឆ្នាំនេះ ។ កាលពីឆ្នាំ ២០០៩ ក្រុមសិស្សពិការ យើងធ្លាប់បានចូលរួមម្តងរួចមកហើយ។ កម្មវិធីនេះគឺជាយុទ្ធនាការឬក៏ជាសារមួយ ក្នុងគោលបំណងជួយឲ្យសាធារណជន យល់ដឹងអំពីគ្រោះថ្នាក់ដោយសារគ្រាប់មីន និងរួមគ្នាដើម្បីបំបាត់គ្រាប់មីននៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងពិភពលោក ។

មណ្ឌលអារ៉ូពេ ជាមណ្ឌលមួយរបស់ព្រះសហគមន៍កាតូលិក ផ្តល់ការស្នាក់នៅ ដើម្បីការសិក្សារបស់កុមារ និង យុវជនពិការ ជាពិសេសអ្នករងគ្រោះដោយសារគ្រាប់មីន។

យុវជនឡូ រីតា អាយុ ២៥ឆ្នាំ ជាបេក្ខជនម្នាក់ ក្នុងចំណោមអ្នកប្រណាំងទាំង ៥០នាក់ឲ្យដឹងថា ការប្រកួតកីឡាម៉ារ៉ាតុននេះ គឺគាត់ចង់បង្ហាញឲ្យអ្នកដទៃបានឃើញ ពីសមត្ថភាព និង ការតស៊ូរបស់ជនពិការ។ រីតា "ខ្ញុំចង់ឲ្យគេឃើញថា អ្នកពិការក៏អាចធ្វើបាន ហើយមានសមត្ថភាពដូចគ្នានឹងអ្នកមានកាយសម្បទាល្អដែរហើយ ពួកយើងក៏មានចិត្តតស៊ូដែរ"។

រីតាបានបញ្ជាក់ថា នេះជាលើកទីពីរហើយ ដែលរូបគាត់បានចូលរួមកម្មវិធីនេះ ដោយប្រណាំងជាមួយរទេះបង្វិលដោយដៃ ក្នុងចម្ងាយផ្លូវ ២១គីឡូម៉ែត្រ ។

លោកឡូ រ៉េន បានបញ្ជាក់ថា សិស្សពិការពីមណ្ឌលអារ៉ូពេ និងចូលរួមការរត់ម៉ារ៉ាតុននេះមាន៣វិញ្ញាសារ គឺរត់ជាមួយជើងសិប្បនិមិត្ត រត់ប្រណាំងជាមួយរទេះបង្វិលកង់ និងរត់ប្រណាំងដោយរទេះបង្វិលដៃ ដោយរត់ក្នុងចម្ងាយ៣គីឡូម៉ែត្រ ១០គីឡូម៉ែត្រ និង២១គីឡូម៉ែត្រ ៕

# ព្រះសហគមន៍ប៉ោយប៉ែតមានព្រះវិហារថ្មី



លោកគីគេនិងក្រុមរបាំរូបថតអនុស្សាវរីយ៍ជាមួយលោកម៉ាកូសអាន ។រូបថតៈ ឡុង សម្មស្ស

ព្រះវិហារសន្តីម៉ារីម៉ាដាឡា នៃព្រះសហគមន៍ប៉ោយប៉ែត បានសម្ពោធឲ្យប្រើប្រាស់ជាផ្លូវការ កាលពីថ្ងៃទី០៤ ខែ មករា ក្រោមអធិបតីរបស់លោកហ្វីការេដូ គីគេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគ បាត់ដំបង លោកង៉ោ ម៉េងស្រ៊ុន ជាអភិបាល នៃគណៈអភិបាលក្រុងប៉ោយប៉ែតលោកប្រាក់ សុភ័ណ្ឌ ជាអនុប្រធានមន្ទីរធម្មការ និង សាសនាខេត្តបន្ទាយមានជ័យ លោក ម៉ាកូសអាន ជាម្ចាស់ជំនួយមកពីប្រទេសកូរ៉េ រួមនឹងបងប្អូនគ្រីស្តបរិស័ទមកពីព្រះសហគមន៍នានាក្នុងភូមិភាគបាត់ដំបងប្រមាណជាង១០០០នាក់ចូលរួម។

ក្នុងពិធីនោះ លោកអភិបាល គីគេ បានមានប្រសាសន៍ថា ក្នុងឱកាសឆ្នាំថ្មីនេះ ព្រះសហគមន៍មានព្រះវិហារថ្មី ដូច្នេះសូមឲ្យគ្រីស្តបរិស័ទយកចិត្តទុកដាក់បំពេញតួនាទីរបស់ខ្លួន ដោយចូលរួមថ្វាយបង្គំព្រះជាម្ចាស់ និងអធិដ្ឋានឲ្យបានច្រើន ដើម្បីឲ្យជីវិតយើងកាន់តែជិតស្និទ្ធជាមួយព្រះជាម្ចាស់។ លោកអភិបាលបន្តទៀតថា ព្រះវិហារថ្មីជាកន្លែងប្រកាសដំណឹងល្អ ដល់អ្នកក្រីក្រ អ្នកទន់ខ្សោយ ជនពិការ ស្ត្រីមេម៉ាយដោយជួយឲ្យពួកគេមានចិត្តសង្ឃឹមក្នុងជីវិតរស់នៅ។ យើងធ្វើកិច្ចការនេះគឺយើងជឿថា ព្រះជាម្ចាស់ព្រះអង្គស្រឡាញ់យើងគ្រប់ៗគ្នា។

លោកអភិបាល បន្ថែមទៀតថា សូមបងប្អូនគ្រីស្តបរិស័ទនៅទីនេះចេះស្វាគមន៍អ្នកដែលមកពីចំងាយហើយ ត្រូវចេះថែរក្សាព្រះវិហារនេះសម្រាប់កូនចៅជំនាន់ក្រោយៗទៀត។

លោកប្រាក់ សុភ័ណ្ឌ ប្រធានមន្ទីរធម្មការនិងសាសនា ខេត្តបន្ទាយមានជ័យបានថ្លែងថាក្នុងខេត្តបន្ទាយមានជ័យកន្លងមកមាន សុខដុមនីយកម្មរវាងសាសនា និង សាសនាដោយមានការសហការគ្នាទៅវិញទៅមក។ លោក សុភ័ណ្ឌ បន្ថែមថា "ខ្ញុំមានមោទនភាពណាស់ ដែលគ្រីស្តសាសនា និង ព្រះពុទ្ធសាសនាមានការទំនាក់ទំនងគ្នាបានល្អ និងមានផ្លាស់ប្តូរទំនៀមទំលាប់ ប្រពៃណីរវាងសាសនា និង សាសនា។ ការទំនាក់ទំនងគ្នាល្អ ពីគ្រប់សាសនាទាំងអស់ជាការនាំឲ្យសង្គមទទួលបាន សុខដុមរមនីយកម្មផ្នែកខាងសាសនា"។

ព្រះវិហារសន្តី ម៉ារីម៉ាដាឡា នៃព្រះសហគមន៍ប៉ោយប៉ែត បានសាងសង់អស់ទឹកប្រាក់ចំនួន ជប់មួយម៉ឺនដុល្លារអាមេរិក ក្រោមជំនួយឧបត្ថម្ភពី លោក ម៉ាកូសអាន និងក្រុមគ្រួសារជនជាតិកូរ៉េ៕

**ដោយឡុង សម្មស្ស**



# ក្រុមសន្តរ៉ាំងសង់ ដឺប៉ូលពីសិង្ហបុរីជួយប្រជាជននៅមណ្ឌលគិរី



ព្រះសហគមន៍កាតូលិក ប៊ូស្រា ទទួលក្រុមសន្តវ៉ាំងសង់ដឺប៉ូល ពីប្រទេសសិង្ហបុរី ចំនួន១៨នាក់ ដើម្បីធ្វើសកម្មភាពសប្បុរសធម៌ ជាមួយអ្នកភូមិក្រីក្រ និង កុមារតាមសាលារៀន កាលពីថ្ងៃទី ២៩ វិច្ឆកា-០៥ ធ្នូ ស្ថិតនៅភូមិឡាំម៉ះ ឃុំប៊ូស្រា ស្រុកពេជ្រដា ខេត្តមណ្ឌលគិរី។

លោកអើនីស ប៉ូ(Ernest Pho) ជាប្រធានសមាគមសន្តវ៉ាំងសង់ដឺប៉ូល ប្រចាំប្រទេសសិង្ហបុរីបានឲ្យដឹងថា៖ គាត់ពិតជាមានមោទនភាព និង អំណរសប្បាយរីករាយមែនតែន ដែលមានឱកាសបានមកបំពេញ បេសកកម្មជួយអ្នកក្រីក្រនៅប្រទេសខ្មែរ ។ គាត់បន្តថា យើងមកទីនេះ គឺចង់បំពេញតម្រូវការគ្រួសារក្រីក្រមួយចំនួន តាមភូមិតូចៗ និងបង្ហាញសេចក្តីស្រលាញ់របស់ព្រះយេស៊ូ ដល់អ្នកក្រីក្រ។ គាត់បានបន្តទៀតថា បេសកម្មនេះ គាត់បានធ្វើវាអស់រយៈពេល៤ឆ្នាំ រួចមកហើយនៅប្រទេសខ្មែរហើយលើកនេះគឺជាឆ្នាំទី៥តែជាលើកដំបូងដែល យើងទាំងអស់គ្នា បានចុះមកខេត្តមណ្ឌលគិរីនេះ។ គាត់បានបន្ថែមថា យើងទាំងអស់គ្នា នឹងបន្តបេសកម្មនេះជារៀងរាល់ឆ្នាំបន្តទៅទៀត នៅប្រទេសខ្មែរ។

កញ្ញា ចយ តែ(Joy Tay) ជាសមាជិកម្នាក់ ក្នុងសមាគមសន្តវ៉ាំងសង់ដឺប៉ូលមកពីប្រទេសសិង្ហបុរី បាននិយាយថា ៖ គាត់ពិតជារីករាយក្នុងការមកជួយគ្រួសារក្រីក្រ និងកុមារនៅប្រទេសកម្ពុជាណាស់ ហើយពួកគាត់ក៏ទទួលបានបទពិសោធន៍ និង រៀនបានច្រើនពីប្រជាជន នៅតំបន់នេះផងដែរ។ ស្ត្រីរូបនេះបន្តថា "ពេលយើងទាំងអស់គ្នានៅប្រទេសខ្មែរនិងជួយអ្នកក្រីក្រ យើងពិតជាមានអារម្មណ៍ថា ពួកយើងពិតជាបាននៅកៀកព្រះជាម្ចាស់មែនតែនគឺតាមរយៈស្នាមញញឹម និង ពាក្យថាអរគុណចេញពីចិត្តរបស់គ្រួសារ និង កុមារៗនៅទីនេះ"។

ចយ តែបន្តថា នៅប្រទេសគាត់មនុស្សធ្វើការ និងរកលុយបានច្រើន តែពួកគាត់គ្មានពេលវេលាចែកបទពិសោធន៍រវាងគ្នា និងគ្នា គ្មានពេលវេលាច្រើន ដើម្បីសួរសុខទុក្ខអ្នកដទៃ និងគ្មានពេលវេលាច្រើនដើម្បីបង្ហាញ សេចក្តីស្រលាញ់របស់ព្រះយេស៊ូ ដល់អ្នកនៅជុំវិញខ្លួនយើងទេ។ គាត់បន្ថែមថា " នៅទីនេះ (កម្ពុជា) យើងបានបំពេញបេសកកម្មដ៏ធំសម្រាប់ បងប្អូនក្រីក្រ និង បានប្រកាសដំណឹងល្អ ដល់អ្នកដែលមិនទាន់ស្គាល់ព្រះសគមន៍យើងផងដែរ"។

សកម្មភាពរបស់ក្រុមនេះរួមមាន ៖ ជួសជុលផ្ទះឲ្យគ្រួសារចំនួនពីរគ្រួសារ ចែកសំភារៈ និង ម្ហូបអាហារសម្រាប់គ្រួសារក្រីក្រចំនួន ២០គ្រួសារ ទិញសំភារៈក្មេងលេង សម្រាប់សាលាមត្តេយ្យព្រះសហគមន៍ប៊ូស្រា ចែកសំភារៈសិក្សា និង ខោអាវដល់សិស្សសាលាសមាគមតូចមួយ នៅខេត្តមណ្ឌលគិរី បង្រៀនអនាម័យដល់កុមារនៅប៊ូស្រា និង ប្រារព្ធពិធីបុណ្យណូអែលសម្រាប់ចាស់ៗ។

អ្នកមីងពឿង អាច ជាគ្រួសារមួយដែលក្រុម បានជួយជួសជុលផ្ទះឲ្យបានមានប្រសាសន៍ ទាំងទឹកមុខញញឹម និង លើកដៃសំពះថា ៖ "ខ្ញុំសប្បាយណាស់ និង សូមអរគុណច្រើនដល់ក្មួយៗទាំងអស់គ្នាបានជួយផ្ទះមីង"។ ដោយការនិយាយខ្មែរមិនសូវច្បាស់គាត់បន្តថា មីងគ្មានអ្វីឲ្យទេ មានតែពាក្យអរគុណតែប៉ុណ្ណឹងហើយ សូមឲ្យក្មួយ មកទៀតពេលក្រោយណា។

សកម្មភាសប្បុរសនេះ ក៏មានការចូលរួមជួយ និង ធ្វើជាគណៈកម្មការ ដោយលោកយ៉ូហាន យេស៊ូសាឡ សាណូជាបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍នោះផ្ទាល់ លោកផាន ប៉ូរ៉ាជាប្រធាន សមាគមសន្តវ៉ាំងសង់ដឺប៉ូលប្រចាំប្រទេសកម្ពុជា យីប រ៉ូស ជាជំនួយការក្រុមយុវជន ផា សុជាតិ និង លោកហេង រ៉ាវីជាសមាជិកក្រុមនេះផងដែរ ហើយព្រមទាំងមានការចូលរួមពីលោក ស្រឿយ ង៉ោគ ជាម្ចាស់ផ្ទះនៅទីនោះផងដែរ៕

**រូបថតនិងអត្ថបទដោយហេង រ៉ាវី**

# យុវជនស្វែងយល់អំពីភាពជោគជ័យក្នុងជីវិត

យុវជន នៃព្រះសហគមន៍កាតូលិកកំពង់ចាមក្រុង ជាង៥០នាក់ បានចូលរួមសិក្ខា សាលាខ្លីមួយស្តីអំពី "គន្លឹះនៃភាពជោគជ័យក្នុងជីវិត" ស្ថិតនៅមណ្ឌល សិស្សប្រុសរបស់ព្រះសហគមន៍ កាតូលិកក្នុងខេត្តកំពង់ចាមស្ថិតនៅភូមិទី១៥ សង្កាត់កំពង់ចាមក្រុង នាថ្ងៃទី៧ មករា។

"ខ្ញុំភ្ញាក់ផ្អើល ហើយនឹកខ្លួនឯងថា "ខ្លួនឯងកំពុងស្ថិតនៅជាមនុស្សបែបណា?" ហើយតើត្រូវកែប្រែ និងធ្វើអ្វីបន្ថែមទៀតក្នុងជីវិត?" នេះជាសំដីរបស់យុវនារី លីម ចន្ថា ជាសិក្ខាកាម មកពីមណ្ឌលសិស្សស្រី នៃព្រះសហគមន៍កាតូលិកកំពង់ចាមក្រុង។

ចន្ថាបន្ថែមថា ក្រោយពីសិក្ខាសាលានេះមកនាងយល់ថា នាងដូចជាមនុស្សថ្មីម្នាក់ និង ធ្វើឲ្យនាងយល់ពីតម្លៃនៃការរៀនសូត្រ និងនាងមានការតាំងចិត្តខ្ពស់ ក្នុងការខិតខំរៀនសូត្របន្តទៀត។ នាងសង្ឃឹមថា ព្រះសហគមន៍កាតូលិកយើង នឹងមានវគ្គសិក្ខាសាលាបែបនេះបន្តទៀតនៅពេលណាមួយ ដើម្បីជាគំនិតដាស់តឿនដល់សិស្សទាំងអស់ ខិតខំប្រឹងរៀន និងមិនអស់សង្ឃឹមក្នុងការជំនះទុក្ខលំបាកនៃការរៀនសូត្រ និងកិច្ចការងាររបស់ពួកគាត់ម្នាក់ៗ។

ស្រដៀងគ្នានេះដែរ យុវជន យន ចាន់ណា ជាយុវជនម្នាក់ ដែលបានចូលរួមក្នុងវគ្គ សិក្ខាសាលាខ្លីនេះដែរ មកពីមណ្ឌលប្រុសនៃព្រះសហគមន៍កាតូលិកកំពង់ចាមក្រុង បានឲ្យដឹងដែរថា៖ គាត់យល់ថា សិក្ខាសាលានេះ ពិតជាល្អមែនទែនសម្រាប់យើងទាំងអស់គ្នាលើសកលលោកនេះ ពីព្រោះថា សិក្ខាសាលានេះ បានជួយឲ្យគាត់ មានការគិតបានទូលាយជាងមុន ដឹងពីកំហុសខ្លួនឯង និងបានស្គាល់ពីវិធីសាស្ត្រផ្សេងៗ ក្នុងការដោះស្រាយពេលមានឧបសគ្គ និងជាពិសេសគឺសិក្ខាសាលានេះបានកែប្រែចិត្តឲ្យក្លាយជាមនុស្សរស់នៅក្នុងសន្តិភាពពិតប្រាកដ។

លោក តាំង ភារម្យ ជាគ្រូឧទ្ទេស បានមានប្រសាសន៍ឲ្យដឹងថា៖ វគ្គសិក្ខាសាលាខ្លីមែន តែវាមានអត្ថន័យ និង មានប្រយោជន៍ច្រើនសម្រាប់សិស្សានុសិស្សទាំងអស់គ្នា ដើម្បីជួយពង្រឹងផ្នែកស្មារតី និង ការគិតរបស់សិស្សានុសិស្សទាំងអស់ ឲ្យមានដំណើរការល្អ គឺមានស្មារតីរឹងពឹង និងមានភាពទុកចិត្តលើខ្លួនឯង មានការគិតបានធំទូលាយ និង គិតអ្វីៗជាចំណុចវិជ្ជមានសម្រាប់ខ្លួនឯង។

លោកគ្រូភារម្យបន្ថែមថា ការសិក្ខាសាលា គាត់បានបង្ហាញគន្លឹះ ១០ យ៉ាងនោះមានដូចជា៖ ១. ការយល់ឃើញត្រូវ ២. មនុស្សកើតមកដើម្បីជោគជ័យ ៣. ការគិតគឺជាអំណាច ៤.ការស្គាល់ពីដែនកំណត់ ៥.យើងជាផលនៃអ្វីៗដែលយើងបានគិត ៦. ការគ្រប់គ្រងវាសនា ៧.ការគិតនូវកំរិតផ្សេងៗគ្នា ៨.ការយកគំរូតាមសកលលោក ៩.ធ្វើជាចំណែកនៃដំណោះស្រាយ និង ១០.ជោគជ័យគឺជាទម្លាប់។

លោកគ្រូបានបន្ថែមថា ក្រៅពីចំណុចទាំង១០នេះ គឺយើងត្រូវអនុវត្តមាន ជីវិត-សេចក្តីស្រលាញ់-រៀនការដឹកនាំ -បន្សល់ទុកស្នាដៃរបស់យើងម្នាក់ៗ។

**ដោយហេង រ៉ាវី**

# ព្រះសហគមន៍តាខ្មៅបង្កើតសកម្មភាពអប់រំកុមារតូច



រូបថតអនុស្សាវរីយ៍របស់ក្រុមកុមារកាយឫទ្ធិ។ រូបថតៈ ពិសិដ្ឋ

ព្រះសហគមន៍ កាតូលិកតាខ្មៅ បានបង្កើតក្រុមកុមារកាយឫទ្ធិ ដែលរៀន ថ្នាក់មត្តេយ្យ រហូតដល់បឋមសិក្សាដែលមានកុមារចំនួន៣៥នាក់ចូលរួមជារៀងរាល់ថ្ងៃអាទិត្យ។

ចំណុចសំខាន់នៃកម្មវិធីនេះគឺចង់ផ្តល់ការអប់រំដល់កុមារអំពីបំនិនជីវិតខ្លះៗនៅក្នុងសង្គម។ លោកបូជាចារ្យ ម៉ារីយ៉ូ ហ្គេហ្ស៊ី ជាអ្នកទទួលខុសត្រូវមណ្ឌលសកម្មភាព ព្រះសហគមន៍ក្រុងតាខ្មៅ ខេត្តកណ្តាលមានប្រសាសន៍ថា មានក្មេងៗជាច្រើនដែលដើរផ្លូវខុស ដូចជា ការលេងល្បែងស៊ីសង ការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន និងការប្រព្រឹត្តអំពើមិនល្អផ្សេងៗ។ ហេតុនេះ ក្រុមយើងក៏បានបង្កើតឡើង ដើម្បីជួបជុំក្មេងៗរៀងរាល់ថ្ងៃអាទិត្យ មានការបង្រៀនផ្នែកអប់រំ និទានរឿង អនាម័យ ល្បែងកំសាន្ត និងសិល្បៈផ្សេងៗដល់ពួកគេ ក្នុងការជួយជំរុញដល់ពួកគេ ឲ្យចាប់អារម្មណ៍ ចំពោះការសិក្សារបស់គេវិញ។

ក្រុមនេះផងដែរ មានអ្នកណែនាំក្រុមចំនួន ១០នាក់ ដែលជាគ្រីស្តបរិស័ទផង និងពុទ្ធបរិស័ទផង ដែលមកពីបណ្តាលខេត្តផ្សេងៗ។

លោកបូជាចារ្យ ម៉ារីយ៉ូ បន្ថែមថា ពីពេលដំបូងៗ យើងត្រូវដើរប្រមូលក្មេងៗតាមផ្ទះរបស់ពួកគេ សុំឪពុកម្តាយរបស់ពួកគេ ដើម្បីឲ្យកូនៗមកជុំគ្នាព្រោះកុមារទាំងនេះមិនដែលចូលរួមក្នុងសង្គម ដោយគ្មានអាណាព្យាបាលទេ ។ លោកបូជាចារ្យបន្តថា បច្ចុប្បន្ន ក្រុមមួយដ៏តូចនេះកំពុងត្រូវបានអ្នកជិតខាងចាប់អារម្មណ៍ ជាពិសេសចំពោះកុមារតូចៗ ឥឡូវមានកំណើនជារៀងរាល់សប្តាហ៍។ លោកបូជាចារ្យសង្កត់ធ្ងន់ថា នេះគឺជារឿងដែលយើងនឹកស្មានមិនដល់ ដែលនេះជាគំរោងការ មួយរបស់ព្រះជាម្ចាស់បានបង្ហាញឲ្យយើងដឹង ឃើញ និងស្គាល់ព្រះអង្គកាន់តែខ្លាំងឡើងៗ ហើយអ្វីដែលធ្វើឲ្យពួកយើងចាប់អារម្មណ៍នោះគឺភាពក្លាហានរបស់ក្មេងៗក្នុងការខិតខំចូលរួមជាមួយពួកយើងជារៀងរាល់សប្តាហ៍។

លោក សេង ភ័កត្រា ជាអ្នកណែនាំក្រុមកុមារកាយឫទ្ធិ និង ជានិស្សិតមកពីខេត្តកំពតបានឲ្យដឹងថា "គោលបំណងខ្ញុំ ដើម្បីជួយដល់ក្មេងៗឲ្យមានការអភិវឌ្ឍខ្លួនឯង ការចេះគោរពអ្នកដទៃ និង ការចែករំលែកសេចក្តីស្រលាញ់ឲ្យគ្នាទៅវិញទៅមក ជាពិសេសសម្រាប់ក្មេង ដែលកំព្រាគ្មានអ្វីទីពឹង មានឱកាសទទួលការអប់រំពីក្រុមរបស់យើង"។

ព្រះសហគមន៍កាតូលិក តាខ្មៅ ស្ថិតក្នុងភូមិភាគភ្នំពេញ បានបង្កើតឡើងកាលពីដើមឆ្នាំ ២០១៤។ ក្នុងរយៈពេលមួយឆ្នាំកន្លងទៅ ព្រះសហគមន៍បានធ្វើដំណើរសន្សឹមៗ ដោយមានគ្រីស្តបរិស័ទ១គ្រួសារ ហើយបានបង្កើតឲ្យមានសកម្មភាព ផ្នែកមេត្តាករុណា និងអប់រំដើម្បីជួយដល់ប្រជាជនក្នុងតំបន់នោះ៕

**ដោយរី ពិសិដ្ឋ**

# ជំនួបក្រុមគ្រួសារកាតូលិកពីមណ្ឌលសកម្មភាពភ្នំពេញខាងជើងនិងខាងត្បូង

មណ្ឌលសកម្មភាព ភ្នំពេញខាងជើង និងខាងត្បូង នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបចំកិច្ចប្រជុំក្រុមគ្រួសារចំនួន៣០គូដើម្បីចែករំលែកបទពិសោធន៍ជីវិត ជាគ្រួសារនិងការអប់រំកូនតាមជំនឿជាគ្រីស្តបរិស័ទកាតូលិក ដែលបានធ្វើនៅព្រះសហគមន៍សន្តយ៉ូសែប (ផ្សារតូច) កាលពីព្រឹកថ្ងៃ សៅរ៍ ទី២៧ ខែធ្នូ ឆ្នាំ ២០១៤កន្លងមកនេះ ។

លោក កូសម៍ ប្រ៊ុយណូ ជាបូជាចារ្យ ទទួលខុសត្រូវមណ្ឌលសកម្មភាពភ្នំពេញខាងជើង មានប្រសាសន៍ថា កម្មវិធីនេះធ្វើឡើងដើម្បីលើកទឹកចិត្តដល់គូស្រករដែលបានទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍នៅក្នុង ព្រះសហគមន៍កាតូលិក អស់រយៈពេលជាច្រើនឆ្នាំកន្លងមក។ លោកបន្តថា នេះក៏ជាឱកាសមួយ ដល់គ្រួសារនីមួយៗ រិះគិតអំពីពេលវេលាសម្រាប់ការសន្ទនាគ្នា និងចាប់ផ្តើមកសាងទំនាក់ទំនងជាមួយគ្នារវាងគ្រួសារមួយទៅគ្រួសារមួយទៀត រួមនិងការចែករំលែកនូវបទពិសោធន៍នៃជីវិតក្នុងគ្រួសារនីមួយៗជាមួយគ្នាផងដែរ។

នៅក្នុងជំនួបនោះដែរ លោក សេន័យឆាល់ វ៉ាំង់សង់ ជាបូជាចារ្យទទួលខុសត្រូវ មណ្ឌលសកម្មភាពភ្នំពេញខាងត្បូងឲ្យដឹងដែរថា ក្នុងជំនួបនេះបានលើកយកនូវ៤ចំណុចសំខាន់ មានដូចជាទី១៖ គឺគុណតម្លៃការសន្ទនាគ្នានៅក្នុងគ្រួសារ គឺជាការផ្តល់នូវតម្លៃឲ្យគ្នារវាងគូស្វាមីភរិយា ចំពោះការសម្រេចចិត្តធ្វើអ្វីមួយ និង របៀបនៃការកសាងទំនុកចិត្តគ្នា នៅក្នុងរង្វង់គ្រួសារ។ ទី២៖ គឺការសន្ទនាគ្នា និងចេះស្តាប់គ្នារវាងប្តីឬប្រពន្ធ ដែលអាចងាយស្រួលរកដំណោះស្រាយ ដើម្បីផលប្រយោជន៍រួមក្នុងគ្រួសារ។ ទី៣៖ ការបញ្ចៀសអំពើហិង្សា នៅក្នុងគ្រួសារ។ទី៤៖ការស្តាប់និងការពិភាក្សាគ្នាដើម្បីបញ្ចៀសបញ្ហាដែលនឹងអាចកើតមានឡើង។

លោកស៊ុយ ប៊ុនថង ប្រធានគណៈកម្មការព្រះសហគមន៍សន្ត យ៉ូសែប បានមានប្រសាសន៍ឲ្យដឹងថា ៖ កម្មវិធីនេះពិតជាមានសារសំខាន់ ចំពោះជីវិតគូស្វាមីភរិយាគ្រីស្តបរិស័ទក្នុងការសន្ទនាជាមួយគ្នា ហើយនិងការជួយបន្តបញ្ជូនជំនឿឲ្យទៅដល់កូនៗរបស់ពួកគេ ។ លោកបន្តថា ការរស់នៅក្នុងជីវិតជាគូស្រករនៅពេលខ្លះ លែងអីតែងតែមាន ការអាក់អន់ចិត្តនឹងគ្នា ហើយក៏មានការខ្វែងគំនិតគ្នាទៅវិញទៅមកដែរ ។ក្នុងជីវិតនេះទោះបីមានបញ្ហាខ្លះៗក្តី ប៉ុន្តែយើងត្រូវចេះដោះស្រាយបញ្ហាជាមួយគ្នា ហើយក៏មានពេលខ្លះ យើងចែករំលែកនូវអំណរសប្បាយជាមួយគ្នាផងដែរ។

លោកបានបញ្ជាក់ថា សម្រាប់ជីវិតគូស្រករគ្រីស្តបរិស័ទទាំងអស់សូមឲ្យចេះសន្ទនាគ្នារវាងប្តី និងប្រពន្ធមានការយោគយល់គ្នា ព្រមទាំងពិភាក្សាគ្នាលើការសម្រេចចិត្តនានា នៅក្នុងរង្វង់គ្រួសារ ដើម្បីភាពសុខដុមរម្យនា និងភាពសុខសាន្តក្នុងក្រុមគ្រួសារ ។

ក្នុងពិធីជួបជុំ ចែករំលែកបទពិសោធន៍ជីវិតគ្រួសារគ្រីស្តបរិស័ទក្រៅអំពីការបកស្រាយ ពីសំណាក់លោកបូជាចារ្យ ក៏មានចោទជាសំនួរចម្លើយ ហើយត្រូវបានបញ្ចប់បន្ទាប់ពីមានការអធិដ្ឋានរួមគ្នា ជាមួយមតិផ្តាំផ្ញើរបស់លោកបូជាចារ្យប្រ៊ុយណូទាក់ទងទៅនឹងសេចក្តីស្រឡាញ់ ដែលព្រះជាម្ចាស់បានប្រទាន ឲ្យដល់ក្រុមគ្រួសារនីមួយៗ។ បន្ទាប់មកទៀត មានការចែកនូវវត្ថុអនុស្សាវរីយ៍ ហើយនិងថតរូបរួមគ្នាទុកជាអនុស្សាវរីយ៍រវាងក្រុមគ្រួសារទាំងអស់ ព្រមទាំងពិសារអាហារជាមួយគ្នា ក្រោមបរិយាកាសសប្បាយរីករាយយ៉ាងក្រៃលែង៕

**ដោយឡុង សម្ផស្ស**

# មណ្ឌលបន្ទាយព្រាបបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការ



លោកជាវ តាយ អភិបាលរងខេត្តកណ្តាលថ្លែងបិទវគ្គសិក្សាសម្រាប់សិស្សជំនាន់២៧។

មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការបន្ទាយព្រាបបានរៀបចំបិទវគ្គសិក្សាសម្រាប់សិស្សជំនាន់ទី២៧ ក្រោមអធិបតីភាពរបស់លោក ជាវ តាយ ជាអភិបាលរង ខេត្តកណ្តាល លោកបូជាចារ្យ ហ្វ្រង់ស៊ីស្កូ អូអ៊ីនដុន ជាប្រធានក្រុមគ្រួសារ សហជីវិនព្រះយេស៊ូរួមជាមួយអាជ្ញាធរ មន្ត្រីរាជការ លោកគ្រូអ្នកគ្រូ និងសិស្សប្រមាណ ២០០នាក់ កាលពីថ្ងៃទី១៨ ធ្នូ កន្លងទៅ។

យុវជននាក់ ឌី ដែលទើបរៀនចប់វគ្គអេឡិចត្រូនិចនៅមណ្ឌលនេះបានឲ្យដឹងដែរថា "ខ្ញុំរៀនអំពីជួសជុលវិទ្យុ ម៉ាញ៉េ ទូរទស្សន៍ ឌីវីឌី និងទូរទស្សន៍អែលស៊ីឌីដែរ។ ខ្ញុំមានសង្ឃឹមជានិច្ច ហើយបន្ទាប់ពីរៀនចប់ខ្ញុំគិតថា ខ្ញុំអាចចិញ្ចឹមឪពុកម្តាយខ្ញុំបាន ទោះបីខ្ញុំជាជនពិការ។ ខ្ញុំជឿជាក់ ខ្ញុំមានជំនាញ ខ្ញុំពិតជាជោគជ័យ"។

នាក់ ឌី ជាជនពិការជើងកាលពី ៣ឆ្នាំមុន ដោយធ្លាក់ពីលើដើមដូង។ យុវជនអាយុ២២ឆ្នាំរូបនេះបានបន្ថែមទៀតថា គាត់ធ្លាប់អស់សង្ឃឹមនិងបានព្យាយាមបង្អត់បាយមិនចង់រស់ព្រោះតែពិការភាពរបស់ខ្លួន។ ប៉ុន្តែគាត់គិតថា ប្រសិនបើជនពិការទាំងអស់គិតអំពីភាពពិការរបស់ខ្លួននោះ ពួកគេនឹងមិនអាចធ្វើអ្វីបានឡើយ។ ឌី និយាយថា "កុំឲ្យអ្នកមិនពិការមើលងាយយើងឲ្យសោះ។ យើងត្រូវតែខំឲ្យជោគជ័យ ត្រូវរៀនជំនាញអីនឹងគេ"។

សិស្សបញ្ចប់ការសិក្សា ជំនាន់ទី២៧នេះមានចំនួន១០៩នាក់ ដែលមានជំនាញដូចជា ស្បែកជើង កាត់-ដេរ អេឡិចត្រូនិច កសិកម្ម ជួសជុលម៉ូត និងចំលាក់។

អង្គុយលើរទេះកង់ យុវតីតាន់ ស្រីវ៉េ អាយុ២៣ឆ្នាំជាសិស្សផ្នែកកាត់ដេរ បានឲ្យដឹងថាការរៀននៅមណ្ឌលនេះនាងមិនបានចំណាយអ្វីឡើយ សូម្បីតែរបស់របរប្រើប្រាស់ផ្ទាល់ខ្លួន ក៏មណ្ឌលបានផ្តល់ជូនរូបនាងដែរ ។ តាន់ ស្រីវ៉េ "អាហារ សំភារៈប្រើប្រាស់មានម៉ាសព្វ អត់មានចំណាយអីទេ"។ ទោះបីជើងរបស់នាងស្វិតទាំងសងខាងតែស្ត្រីរូបនេះ នៅតែពុះពាររៀនជំនាញកាត់ដេរ ដោយប្រើដៃទាំងពីររបស់នាង។ ស្រីវ៉េ "ពិបាកដេរពេលដេរ។ ធម្មតាគេប្រើជើងជាន់ម៉ូទ័រ តែខ្ញុំប្រើដៃម្ខាងសង្កត់ម៉ូទ័រ ហើយម្ខាងទៀតរុញក្រណាត់ ។ អាចដេរបាន"។

ស្រីវ៉េ មកពីខេត្តកំពង់ធំ និងបានរៀនត្រឹមថ្នាក់ទី៤ប៉ុណ្ណោះ។ នាងបានស្គាល់មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការបន្ទាយព្រាប តាមរយៈមិត្តភ័ក្ររបស់នាង។ ក្រោយពីបញ្ចប់ការសិក្សានៅមណ្ឌលនេះ ស្រីវ៉េចង់ទទួលបានការងារមួយដែលសមស្របតាមកំលាំងរបស់នាង ឬរកឱកាស និងថវិការ ដើម្បីបើកហាងកាត់ដេរនៅភូមិស្រុករបស់នាង។

លោកជុំ គឿន អាយុ៣១ឆ្នាំមកពីស្រុកស្ទឹងត្រង់ខេត្តកំពង់ចាម ឲ្យដឹងដែរថា ជីវិតពិការរបស់លោកត្រូវបានផ្លាស់ក្រោយពេល លោកបានស្គាល់មណ្ឌលបណ្តុះបណ្តាលមួយនេះ ។ លោកគឿនបានប្រាប់ថា "ជីវិតប្រែក្លាយជាថ្មីខុសពីមុន។ នៅទីនេះពួកគាត់បង្រៀនឲ្យយើង ចេះគិតច្រើន ដូចជា ថវិកាត្រូវចេះចាយវាយឲ្យល្អ ចេះទុកដាក់វា ខ្ញុំគិតថាវាល្អសម្រាប់ជីវិតរបស់យើង"។

លោកបន្តថា "នៅពេលនេះខ្ញុំសប្បាយចិត្តព្រោះខ្ញុំអាចធ្វើបានមានជំនាញមួយ ដូចមានទ្រព្យសម្បត្តិគ្រប់យ៉ាងក្នុងខ្លួន។ ខ្ញុំគិតថា ឥឡូវខ្ញុំមានដៃជើងគ្រប់គ្រាន់ ដូចអ្នកដែលមានកាយសម្បទានគ្រប់គ្រាន់ដែរ"។ អង្គុយលើរទេះកង់ ព្រោះជើងពិការ លោកបន្ថែមថា " ខ្ញុំតែងគិតថា ខ្ញុំអត់ពិការទេ។ ជនពិការ លុះត្រាតែបាត់បង់សតិបញ្ញា"។

សព្វថ្ងៃលោកជុំគឿន ជាគ្រូជំនាញផ្នែកជួលជុលទូរស័ព្ទដៃ នៅមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ជនពិការបន្ទាយព្រាប។

លោកបូជាចារ្យ ហ្វ្រែគ ព្រីយ៉ាឌី ជាប្រធានមណ្ឌល បណ្តុះបណ្តាលវិ-ជ្ជាជីវៈជនពិការបន្ទាយព្រាបបានមានប្រសាសន៍ថា គោលដៅនៃមណ្ឌលនេះ គឺចង់លើកកម្ពស់ដល់សិទ្ធិជនពិការ សេចក្តីថ្លៃថ្នូររបស់ពួកគាត់ និងផ្តល់នូវភាពជឿជាក់ ដល់ជនពិការទាំងនោះ។ លោកបូជាចារ្យ ហ្វ្រែគ បន្តថា ក្រោយពេលសិស្សរៀនចប់ពីមណ្ឌលនេះទៅសាលាក៏មានផ្តល់ជូននូវដើមទុនខ្លះៗដើម្បីឲ្យពួកគាត់អាចប្រកបការងារចិញ្ចឹមជីវិត របស់ខ្លួនបាន។ លោកបូជាចារ្យបន្តថា មុនពេលផ្តល់ទុន យើងត្រូវមើលដែរ បើគាត់មានឆន្ទៈធ្វើវាឬអត់។ ហើយពួកគាត់ត្រូវបង្វិលទុននោះមកវិញក្រោយពេលមុខរបរដំណើរការ។ ការធ្វើរបៀបនេះ នោះនាំឲ្យគាត់យល់ថាកិច្ចការដែលគាត់កំពុងធ្វើមានតម្លៃ។

លោកបូជាចារ្យ ហ្វ្រែគ បន្តថាក្នុងមណ្ឌលវិជ្ជាជីវៈនេះ មានបង្រៀនជំ-នាញ ដើម្បីទ្រទ្រង់សេដ្ឋកិច្ចសម្រាប់ជនពិការ និងរបៀបនៃការរស់នៅក្នុងសង្គម។

លោកបានបន្ថែមទៀតថា ក្នុងរយៈពេលជាង២០ឆ្នាំនេះ មណ្ឌលបានបណ្តុះបណ្តាល សិស្សប្រមាណជាង ១៦៩៨នាក់ ហើយមាន៩០ភាគមានការងារធ្វើ ឬប្រកបការងារដោយខ្លួនឯង រីឯ១០ភាគរយទៀតគឺពួកគាត់ ស្ថិតនៅក្នុងកំរិតជនពិការដែលមិនអាចរៀន ជំនាញបានទេ ដោយមណ្ឌលបង្រៀន នូវរបៀបនៃការចូលរួម និង របៀបរស់នៅក្នុងសង្គមវិញ។

មណ្ឌលបណ្តុះបណ្តាល វិជ្ជាជីវៈជនពិការបន្ទាយព្រាប បង្កើតឡើងក្នុងឆ្នាំ ១៩៩១ ជាស្ថាបនមួយរបស់អង្គការជេស្វីតសឺវីសកម្ពុជា ដែលធ្វើការដើម្បីលើកកម្ពស់ជនពិការ ដោយបើកបង្រៀននូវជំនាញខ្លីៗរយៈពេល ៦ខែដល់២ឆ្នាំ លើមុខជំនាញដូចជាជំនាញ ជួសជុលគ្រឿងម៉ាស៊ីន អេ-ឡិចត្រូនិច កាត់ដេរ(ស្បែកជើង និងសំលៀកបំពាក់) កសិកម្ម សិប្បកម្ម និងចំលាក់។ក្រៅពីនោះក៏មានកម្មវិធីមួយចំនួនទៀតផងដែរ ដូចជា ផលិតរទេះជនពិការ កម្មវិធីអភិវឌ្ឍសហ-គមន៍ និងផ្នែកសិប្បកម្ម។

នាពេលអនាគតខាងមុខ មណ្ឌលនេះនឹងរៀបចំទទួលអ្នកពិការ សតិ-បញ្ញា និង បង្រៀនលើមុខជំនាញបន្ថែមផ្នែកតុបតែងមុខផងដែរ។

**ដោយកញ្ញា**


លោកបូជាចារ្យ ហ្វ្រែគ ផ្តល់វិញ្ញាបនបត្របញ្ជាក់ការសិក្សាដល់សិស្សជំនាន់ទី២៧



លោកតា វ៉ាបាំង

## មរណសាក្សីកម្ពុជា៖

# ប្រវត្តិរូបរបស់លោកវ៉ាបាំង

(តពីលេខមុន)

នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧២ ស្រាប់តែលោកឪពុក មីសែល តាន់ ទទួលមរណភាព ដោយជម្ងឺគាំងបេះដូង លោកតាន់នេះ ជាបូជាចារ្យវៀតណាមទទួលបន្ទុកលើព្រះសហគមន៍បឹងកញ្ជោត។ នៅក្នុងថ្ងៃជាមួយគ្នានោះ លោក ឡៀវ៉ាន់ឌឹង បានអញ្ជើញទៅសួរសុខទុក្ខគ្រីស្តបរិស័ទនៅក្រុងក្រចេះ។ នៅវេលាម៉ោង ៥ ល្ងាច ពួកវៀតកុងបានអញ្ជើញលោកឲ្យទៅតាមពួកគេ។ លោកដឹងខ្លួនថា ជីវិតរបស់លោកមុខជាអន្តរាយជាក់ជាមិនខាន។ ដូចច្នេះ លោកក៏យកអាវបំពង់របស់លោកបូជាចារ្យមកពាក់។ ពួកគេនាំលោកយកទៅឃុំក្នុងសាលារៀនមួយ រួចយកទៅឃុំក្នុងផ្ទះមួយចំងាយប្រហែល ២ គ.ម.ខាងជើងក្រុង។នៅយប់ថ្ងៃទី២១ខែមីនា ពួកគេនាំលោកទៅទាំងចងស្លាបសេក។ នៅថ្ងៃបន្ទាប់មានគ្រីស្តបរិស័ទម្នាក់ ដែលតែងតែយកអាហារតិចតួច មកជូនលោក ឃើញបុរសម្នាក់ ពាក់អាវរបស់លោកបូជាចារ្យ ក៏ប៉ុន្តែបុរសនោះ មិនមែនលោកឪពុក ឌឹង ទេ! ប្រហែលជាគេយកគាត់ទៅសម្លាប់ ក្នុងពេលយប់នោះហើយ។

នៅពេលយប់ថ្ងៃទី ២៣ និង ២៤ ខែកុម្ភៈ ឆ្នាំ១៩៧២ គ្រាប់មីនដែលពួកខ្មែរក្រហមដាក់ជិតខ្ទមលោក វ៉ាបាំង បានផ្ទុះឡើង បណ្តាលឲ្យលោកដែលសម្រាន្តក្នុងផ្ទះនោះ ត្រូវបាក់ជើង និងរងរបួសពេញខ្លួន។ ទោះបីជាឈឺជាទំងន់យ៉ាងណាក៏ដោយ ក៏លោកនៅតែដឹងស្មារតី ហើយសួរ កេ ជាកូនធម៌ថា៖ "កេអើយ! កើតអ្វីមិញ? តើគេបានដាក់គ្រាប់មីនមែនទេ?"។ កេឆ្លើយថា៖ "មែន។ លោកដឹងហើយ គេចង់សម្លាប់លោកមែនទែន" ។ លោក វ៉ាបាំង ងក់ក្បាលសម្លឹងមើលទៅកេ ហើយនិយាយទៅគាត់ថា ៖ "កូនអើយ...ប្រសិនបើគេចាប់អ្នកដែលបានព្យាយាមសម្លាប់ខ្ញុំ ចូរអត់ទោសឲ្យគេ កុំធ្វើបាបដល់គេឡើយ! វាគ្មានប្រយោជន៍ទេ... កូនអើយ... ចូរទុកចិត្តលើព្រះជាម្ចាស់ចុះ... ខ្ញុំបានស្រឡាញ់គ្រីស្តបរិស័ទទាំងអស់គ្នាយ៉ាងខ្លាំង!"

ពេលឮសម្លេងគ្រាប់ផ្ទុះឡើងគ្រីស្តបរិស័ទមានការភ្ញាក់ផ្អើល ជាខ្លាំង ហើយនាំគ្នាស្វែងរកទីតាំងដែលមានសូរសម្លេងផ្ទុះ រហូតបានដឹងថា វាកើតឡើង នៅកន្លែងស្នាក់នៅរបស់លោក វ៉ាបាំង។ ពេលទៅដល់ទីនោះហើយ ពួកគាត់ឃើញលោកទទួលរងគ្រោះថ្នាក់ និង លោកកេ ជាមួយប្រពន្ធកំពុងជួយរុំរបួសទប់ឈាម។ ពួកគាត់ក៏ស្ទុះជួយដែរ។ គ្រីស្តបរិស័ទខ្លះបានយកក្រណាត់ដែលជូតឈាមទៅថែរក្សាទុក ពីព្រោះគេចាត់ទុកឈាមនេះ ជាឈាមដ៏មានតម្លៃ ដែលលោក វ៉ាបាំង បានបង្ហូរសម្រាប់ពួកគាត់ និង ជាឈាមមរណសាក្សី ។

ពួកខ្មែរក្រហម បង្គាប់ឲ្យគ្រីស្តបរិស័ទយក លោក វ៉ាបាំង ទៅដល់មន្ទីរពេទ្យ។ លោកកេ ជាមួយយុវជនខ្លះសែងលោកបូជាចារ្យ ដោយថ្មើរជើងទៅមន្ទីរពេទ្យនៅក្រូចឆ្មារចំងាយ ៩គ.ម.។ លុះដល់ទីនោះ ប្រហែលម៉ោង៧ ព្រឹក ពួកយុវជនត្រឡប់ទៅវិញ លើកលែងតែ ៣នាក់ ដើម្បីជួយយាមលោក។ ប៉ុន្តែគ្រូពេទ្យមិនរវីរវល់នឹងលោកទេ។ ដោយគ្រីស្តបរិស័ទព្យាយាមដាស់តឿនគ្រូពេទ្យ គ្រូពេទ្យឲ្យពួកគេទិញថ្នាំ៣០មុខ! ឮដូច្នេះ ពួកគ្រីស្តបរិស័ទបបួលគ្នាទៅរកទិញថ្នាំនោះ ហើយបានតែ ២០មុខប៉ុណ្ណោះ។ ដោយចាក់ថ្នាំនោះហើយ លោក វ៉ាបាំង បានធូរវិញ។

ដល់ម៉ោង២រសៀល ពួកខ្មែរក្រហមប្រាប់ដល់គ្រីស្តបរិស័ទថា៖ "ទុកឲ្យយើង យកលោកទៅមន្ទីរពេទ្យតំបន់របស់យើងនៅទីនោះ នឹងបានស្រួលជាង"។ ប៉ុន្តែគេមិនឲ្យគ្រីស្តបរិស័ទទៅជាមួយទេ។ គ្រីស្តបរិស័ទមិនព្រមទេ ហើយស្រែកដាក់ពួកខ្មែរក្រហមថា៖ "បើគ្មានមនុស្សនៅជាមួយ ដើម្បីយាមនោះលោកមុខជានឹងស្លាប់!"។ ពួកវៀតកុង ស្តីដាក់គ្រីស្តបរិស័ទវិញថា៖ " ពួកឯងអត់ចេះដឹងគុណទេឬ ? យើងចង់ជួយពួកឯង តែពួកឯងចេះតែរអ៊ូ!"។ ដូច្នេះពួកខ្មែរក្រហម ដាក់លោក វ៉ាបាំង លើរ៉ឺម៉ក ហើយយកលោកទៅកន្លែងពួកគេ។

នៅថ្ងៃនោះ ម៉ោង៧យប់ ពួកខ្មែរក្រហម ប្រគល់សពរបស់លោកបូជាចារ្យមកឲ្យគ្រីស្តបរិស័ទវិញ ។

ហេតុការណ៍នេះ ធ្វើឲ្យគ្រីស្តបរិស័ទដែលនៅរង់ចាំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះគេមិននឹកស្មានថារបួសនោះ មានលក្ខណៈធ្ងន់ធ្ងររហូតដល់បាត់បង់ជីវិត។ គេសង្ស័យថា វាជា ស្នាដៃរបស់គ្រូពេទ្យខ្មែរក្រហមប្រហែលបានចាក់ថ្នាំសម្លាប់។

ពេលនោះគ្រីស្តបរិស័ទ នាំគ្នាឱនកាយគោរពសពរបស់ លោកឪពុកដែលបានបូជាជីវិតសម្រាប់ពួកគេ ។ ថ្ងៃក្រោយពួកគ្រីស្តបរិស័ទប្រារព្ធពិធីបញ្ចុះសពនៅក្បែរសាលារៀនមួយ។

ចាប់តាំងពីពេលនោះមក នៅក្នុងភូមិក្តុលលើ/ខ្សាច់ប្រទេះ គ្មានលោកបូជាចារ្យទៀតទេ។ គ្រីស្តបរិស័ទវៀតណាមរកផ្លូវរត់គៀសខ្លួនបោះបង់អ្វីៗទាំងអស់ចោលដើម្បីឆ្លងដែន។ រីឯគ្រីស្តបរិស័ទខ្មែរ បន្តរស់នៅក្នុងភូមិដដែលដោយលួចអធិដ្ឋានស្ងៀមស្ងាត់តាមផ្ទះជាមួយនឹងក្រុមគ្រួសារ។

រហូតដល់ឆ្នាំ១៩៩០ លោកតា អង់ដ្រេ ឡឺស៊ូអែហ្វ ជាអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម ចាប់ផ្តើមមកសួរសុខទុក្ខ គ្រីស្តបរិស័ទវិញ។ពីពេលនោះមកដោយសារមានលោកឪពុក ដូនជី និង គ្រីស្តបរិស័ទជាច្រើន ជួយរួបរួមគ្នានាំឲ្យព្រះសហគមន៍ក្តុលលើមានជីវិតរស់ឡើងវិញ។ ឈាមដែលលោកតា វ៉ាបាំង បានបង្ហូរនោះ ក្លាយទៅជាគ្រាប់ពូជ បង្កើតគ្រីស្តបរិស័ទថ្មី។

សូមអរព្រះគុណព្រះជាម្ចាស់!

ព័ត៌មានកាតូលិកអន្តរជាតិ ▪

# វ៉ាទីកង់កំពុងតែរៀបចំធ្វើកំណែទម្រង់ប្រព័ន្ធផ្សព្វផ្សាយកាតូលិក

ទីភ្នាក់ងារព័ត៌មានកាតូលិក បានរាយការណ៍ព័ត៌មានថា លទ្ធផលនៃគម្រោងការធ្វើការកែទម្រង់ប្រព័ន្ធផ្សព្វផ្សាយ របស់ព្រះសហគមន៍កាតូលិក រំពឹងថានឹងលេចចេញជារូបរាងនៅក្នុងរង្វង់ដើមខែមករាខាងមុខ ។

ប្រភពដដែលបានឲ្យដឹងថា គណៈកម្មការប្រព័ន្ធផ្សព្វផ្សាយរបស់បុរីវ៉ាទីកង់បានបញ្ចប់ដំណើរលើកទីបី ដើម្បីទស្សនកិច្ចស្វែងយល់ពីប្រព័ន្ធផ្សព្វផ្សាយវ៉ាទីកង់ ហើយក្រោយពេលបញ្ចប់ទស្សនកិច្ចនេះទៅសមាជិកនៃគណៈកម្មការនេះនឹងទំនងជាពិភាក្សាអំពីលទ្ធផល នៃការសំរេចចិត្តនៅក្នុងរង្វង់ខែក្រោយដើមឆ្នាំក្រោយ។

នៅដំណើរចុះសិក្សា តាមស្ថាប័ន ព័ត៌មាននានា នៅក្នុងបុរីវ៉ាទីកង់សមាជិកគណៈកម្មការបានធ្វើការសិក្សាប្រមូលមតិយោបល់ និង អនុសាសន៍ផ្សេងៗពីបណ្តាអ្នកសារព័ត៌មានទាំងអស់ដែលធ្វើការ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយនៅបុរីវ៉ាទីកង់ នៅក្នុងគោលបំណងនឹងរៀបចំផែនការថ្មី ដើម្បីជំរុញការផ្សព្វផ្សាយដំណឹងល្អប្រកបដោយប្រសិទ្ធិភាព ។

នៅក្នុងព្រះសហគមន៍ប្រព័ន្ធផ្សព្វផ្សាយត្រូវបានគេអះអាងថា គឺជាទីកន្លែងប្រកាសដំណឹងល្អដ៏មានប្រសិទ្ធិភាពមួយ ប៉ុន្តែដោយសារតែការរីកចំរើន នៃគំនិតបច្ចេកវិទ្យាព័ត៌មានព្រះសហគមន៍ ក៏ត្រូវបានគេជំរុញឲ្យមានកំណែទម្រង់ផ្នែកនេះផងដែរ ដើម្បីឲ្យកាន់តែមានប្រសិទ្ធិភាព៕

### ថ្ងៃទី៤ មករា ២០១៥
**(មថ២,១-១២)**

តាំងពីដើមរៀងមក មនុស្សគ្រប់ជាតិគ្រប់សាសន៍ព្យាយាមស្វែងយល់អំពីស្ថានភាពជីវិតរបស់ខ្លួនក្នុងពិភពលោកនេះ ដោយមានទំនាក់ទំនងជាមួយអ្វីមួយដែលគេជឿថា ជាសេចក្ដីពិតនិងជាទីពឹង...។ ប៉ុន្តែដោយព្រឹត្ត-ការណ៍ដ៏អស្ចារ្យ ត្រចះត្រចង់ គឺព្រះបុត្រា បានចាប់កំណើតជាមនុស្សពីរពាន់ឆ្នាំមុន យើងជឿថា ព្រះជាម្ចាស់បានសំដែងព្រះអង្គ ឲ្យមនុស្សគ្រប់ជាតិសាសន៍ អាចស្គាល់ព្រះអង្គ។ មានន័យថា ឥឡូវនេះ មិនមែនជាមនុស្សដែលខំមានទ្រឹស្ដី អំពីសេចក្ដីពិតទៀតទេ គឺជាព្រះអង្គផ្ទាល់ដែលនាំសត្វលោកទាំងអស់ ឲ្យដឹងថា "សេចក្ដីពិត" មានជីវិតនិងមានឈ្មោះជា"សេចក្ដីពិត" ឈ្មោះព្រះយេស៊ូគ្រីស្ដ ជាព្រះអម្ចាស់ដ៏ពិតប្រាកដ និង ជាមនុស្សដ៏ពិត ប្រាកដផង។

"ប្រជាជាតិនានា នាំគ្នាដើរទៅរកពន្លឺរបស់អ្នក ហើយស្ដេចទាំងឡាយក៏ដើរទៅរករស្មីដែលចាំងចេញពីអ្នកដែរ" (អស ៦០,៣)

យើងអធិដ្ឋានជាពិសេស សម្រាប់ស្ដេច និង អ្នកដឹកនាំនានាក្នុងពិភពលោក ដើម្បីពួកគាត់ទៅរកពន្លឺ នៃយុត្តិធម៌និងសេចក្ដីសុខសាន្ត ៖ ឱព្រះអម្ចាស់អើយ សូមយាងមកបំភ្លឺ និងជួយប្រែចិត្តគំនិត អស់អ្នកដែលស្ថិតនៅក្នុងទីងងឹត! ។

### បុណ្យ ព្រះយេស៊ូ ទទួលពិធីជ្រមុជទឹក (មថ១,៧-១១)

ថ្ងៃអាទិត្យនេះ ជាថ្ងៃបង្ហើយរដូវបុណ្យព្រះយេស៊ូប្រសូត។ ថ្ងៃស្អែកយើងចាប់ផ្ដើមរដូវធម្មតាប្រចាំឆ្នាំ ។ មុនព្រះយេស៊ូ ចាប់ផ្ដើមសម្ដែងធម្ម-ទេសនា ព្រះអង្គសូមឲ្យលោក យ៉ូហាន ធ្វើពិធីជ្រមុជទឹកថ្វាយព្រះអង្គ។

" មានឮព្រះសូរសៀងលើ មេឃមកថា ៖ " ព្រះអង្គជាបុត្រដ៏ជាទីស្រឡាញ់របស់យើងគាប់ចិត្តនឹងព្រះអង្គណាស់!"(មក ១,១១)

នៅសម័យនោះ លោក យ៉ូហាន នាំមនុស្សប្រែចិត្តគំនិត ដោយទទួលពិធីជ្រមុជទឹកដើម្បីព្រះជាម្ចាស់លើកលែងទោសឲ្យរួចពីបាប។ តាមពិតព្រះយេស៊ូ មិនត្រូវការទទួលពិធីនេះទេ ព្រោះព្រះអង្គ មិនមែនជាអ្នកបាបព្រះអង្គ។ ប៉ុន្តែដោយទទួលពិធីជ្រ-មុជទឹកពីលោក យ៉ូហាន និងពិធីជ្រ-មុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ពីព្រះអម្ចាស់។ ព្រះយេស៊ូជា "ព្រះគ្រីស្ដ" មានន័យថា "អ្នកដែលបានទទួលប្រេងអភិសេក" តែងតាំងធ្វើជាព្រះសង្គ្រោះ។ សព្វថ្ងៃដោយទទួលអគ្គសញ្ញាជ្រមុជទឹក និង អគ្គសញ្ញាលាបថ្ងាស សត្វលោកទាំងមូលអាចទទួលការសង្គ្រោះបាន។ ប៉ុន្តែកុំគិតថា អគ្គសញ្ញាទាំងពីរនេះ ជាមន្តអាគមន៍! ព្រោះអគ្គសញ្ញា ទាំងពីរនេះតែងតាំងមនុស្ស ឲ្យធ្វើជាគ្រីស្ដបរិស័ទ មានន័យថាស្រឡាញ់ព្រះជាម្ចាស់ជាព្រះត្រៃឯកអស់ពីកំលាំងចិត្ត និងស្រ-ឡាញ់មនុស្សឯទៀតៗ ព្រោះតែព្រះអង្គ និងដូចព្រះអង្គ។ ដូច្នេះគ្រីស្ដ-បរិស័ទ បន្តបេសកកម្មរបស់ព្រះយេស៊ូគ្រីស្ដក្នុងពិភពលោកនេះ។ នេះជាការទទួលខុសត្រូវដែលយើងជាគ្រីស្ដបរិស័ទបានទទួល ពីព្រះជាម្ចាស់...

### ថ្ងៃទី១៨ មករា ២០១៥
**(យហ១,៣៥-៤២)**

" ព្រះអម្ចាស់យាងមកឈរ ... ហើយមានព្រះបន្ទូលហៅ... សាម៉ូអែល! សាម៉ូអែល!" (១សម៣,១០)

នៅពេលចាប់ផ្ដើមរដូវធម្មតា សាជាថ្មីនេះ ព្រះសហគមន៍រំលឹកយើងតាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ថា ព្រះអង្គស្គាល់យើងម្នាក់ៗតាមឈ្មោះរបស់យើង។ សម្រាប់ព្រះជា-ម្ចាស់ យើងម្នាក់ៗមានឈ្មោះ មានសារៈសំខាន់ និងមានតម្លៃ។ យើងមិនមែនកូនកំព្រា នៅចំពោះព្រះជា-ម្ចាស់៖ " ... ដ្បិតព្រះអង្គបានបង់ថ្លៃយ៉ាងច្រើនលើសលប់ ដើម្បីលោះបងប្អូន" (១ករ ៦,២០) ។

តាមរយៈព្រះយេស៊ូគ្រីស្ដ ជាព្រះបុត្រា បានលោះបងប្អូន ដោយបង្ហូរឈាម និងបូជាជីវិតនៅលើឈើឆ្កាង។ ព្រះយេស៊ូបានចងសម្ពន្ធមេត្រីថ្មី ជាមួយសត្វលោកទាំងមូល ៖ ឥឡូវនេះ មនុស្សម្នាក់ៗ អាចទទួលការសង្គ្រោះបាន ពីព្រោះមនុស្សម្នាក់ៗមានតម្លៃមកពី ឈាមរបស់ព្រះយេស៊ូគ្រីស្ដ។ ដូច្នេះ ចូរអរសប្បាយឡើង ព្រោះព្រះអង្គ បានសព្វព្រះហឫទ័យស្រឡាញ់យើង!

### ថ្ងៃទី ២៥ មករា ២០១៥
**(មក ១,១៤-២០)**

ក្នុងអត្ថបទទីមួយព្យាការី យ៉ូណាស់ដាស់តឿនប្រជាជនក្រុងនីនីវេឲ្យប្រែចិត្តគំនិតព្រោះព្រះអម្ចាស់ចង់បំផ្លាញក្រុងរបស់ពួកគេ។ ដូច្នេះ ពួកគាត់ទាំងអស់គ្នា "តមអាហារ និង ស្លៀកពាក់កាន់ទុក្ខ"។ "ពេលព្រះជាម្ចាស់ទតឃើញអំពើដែលពួកគេប្រព្រឹត្ត គឺគេប្រែចិត្តគំនិត ព្រះអង្គមិនបំផ្លាញពួកគេចោលឡើយ" (យណ៣,១០ )។

តាំងពីដើមរៀងមក ព្យាការីទាំងឡាយ ដែលប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅពិភពលោកទាំងមូលមានប្រសាសន៍ថា "ចូរប្រែចិត្តគំនិត..."។ យើងទាំងអស់គ្នា ជាអ្នកបាប ប៉ុន្តែ ប្រសិនបើយើងខំប្រែចិត្តគំនិតរបស់យើងយ៉ាងពិតប្រាកដ ព្រះអង្គមិនសូវចាប់អារម្មណ៍អំពីអំពីហាបរបស់យើងទៀតទេ។ ព្រោះគំរោងការណ៍របស់ព្រះអង្គ ចំពោះមនុស្សលោក គឺជាការសង្គ្រោះ។

" សូមអញ្ជើញមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នកឲ្យនេសាទមនុស្សវិញ" (មក ១,១៧)

ព្រះយេស៊ូគ្រីស្ដជា "មហាបេសកជន"របស់ព្រះបិតា។ ក្នុងផែនដីយើងព្រះអង្គបានប្រកាសដំណឹងល្អនៃការសង្គ្រោះអស់រយៈពេល៣ឆ្នាំ។ ពេលនោះ ព្រះអង្គបានជ្រើសរើសគ្រីស្ដទូត១២រូប ដើម្បីបន្តបេសកកម្មនេះរួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ។ ដូច្នេះព្រះសហគមន៍ បន្តបេសកកម្មនេះដោយ " តែងតាំងយើង ឲ្យនេសាទមនុស្ស" ដើម្បីនាំពួកគាត់ ស្គាល់ដំណឹងល្អ និង ទទួលការសង្គ្រោះបាន។ ក្នុងព្រះសហគមន៍ ព្រះអង្គលើកលែងទោសឲ្យយើង តាមរយៈអគ្គសញ្ញាសម្រុះសម្រួល។ ដោយប្រែចិត្តគំនិតយ៉ាងពិតប្រាកដគ្រីស្ដបរិស័ទហ៊ានរំខានលោកបូជាចារ្យ ដើម្បីទទួលអគ្គសញ្ញាសម្រុះសម្រួល ជាអគ្គសញ្ញានៃសេចក្ដីស្រឡាញ់ របស់ព្រះជាម្ចាស់ចំពោះមនុស្សលោក។ ដើម្បីស្គាល់ និង ឃើញព្រះអង្គ យើងត្រូវតែរស់នៅជាមួយព្រះ អង្គ។ ក្នុងអត្ថបទទី២ សន្តប៉ូលមានប្រសាសន៍ថា "កាយរបស់បងប្អូន ជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលគង់នៅក្នុងបងប្អូន" (១ករ ៦,១៩)។

---

### កំណាព្យ
## តួនាទីឪពុកម្ដាយដើម្បីអនាគតកូន
(បទពាក្យ ៧)

១-នាទីពុកម៉ែថែរក្សា
    ទទួលខុសត្រូវរាល់យប់ថ្ងៃ
ដល់បុត្រធីតាទាំងប្រុសស្រី
រហូតពេញវ័យគ្រប់រូបា។

២-លោកត្រូវគិតពីអនាគត
    ឲ្យកូនទៅរៀនចូលសាលា
ពិសេសបំផុតការសិក្សា
ក្រេបវិជ្ជាការចំណេះដឹង។

៣-អក្សរ.ក.ខ.លេខនពន្ធ
    មាសប៉ុនដួងទុំរាប់តម្លឹង
វិជ្ជាមិនធ្ងន់ទូលវែងថ្លឹង
មិនអាចស្មើនឹងវិជ្ជាបាន។

៤-កូននៅក្មេងខ្ចីវ័យល្ងង់ខ្លៅ
    កុំឲ្យកូនធំលង់ខកប្រាណ
ពុកម៉ែប្រដៅឲ្យថ្កើងថ្កាន
ធ្វើចេះស្មានៗថាមិនត្រូវ។

៥-ក្មេងខ្លះលើកដៃសុំទានគេ
    តាមរមណីយដ្ឋានច្រើនពេកកូវ
ខ្លះនៅតាមឆ្នេរខ្លះតាមផ្លូវ
តើលោកម៉ែឪគិតយ៉ាងណា?

៦-ខ្លះទៀតទើបធំពេញជំទង់
    កម្មកររោងចក្រគេចសាលា
ដាក់ពាក្យចូលក្នុងប្រុងធ្វើការ
គេចការសិក្សាទ្រព្យពិសេស។

៧-ដល់កូនល្ងិតល្ងង់លង់ត្រកូល
    គេពោលថាកូនយើងមិនផេះ
ខាតបង់ចំណូលគ្មានចំណេះ
បើល្ងង់យ៉ាងនេះម្ដេចមិនរៀន។

៨-ពុកម៉ែឈឺចាប់ស្ដាប់ពាក្យគេ
    គេថានឹងមុខសុទ្ធព្រៀងលាន
ថ្វីត្បិតមិនដេរតែនឹកអៀន
ស្ដាយក្រោយឲ្យរៀនកូនជ្រុលហួស។

៩-នេះហើយត្រើយចិត្តគិតមិនច្បាស់
    អាប់មុខអ្នកណាដោយទាំងឈ្មោះ
យល់ខុសស្រឡះដល់កិត្តយស
គ្រាំចិត្តរងគ្រោះព្រោះភ្លេចគិត។

១០-ដូច្នេះសូមចិត្តពិចារណា
    មាតាបិតាម្ចាស់ជីវិត
រើសយកមួយណាដែលល្អពិត
គ្រងរក្សាស្និទកូនគ្រប់គ្នា។

និពន្ធដោយៈ អ្នកស្រី ខុង ណារី

# រូបថតសកម្មភាពព្រះសហគមន៍ទាំងបីភូមិភាគ



លោកអភិបាលជួបជុំជាមួយក្រុមកាយឫទ្ធិនៅតាកែវ



លោកអភិបាលសំណេះសំណាលជាមួយបងប្អូននៅមណ្ឌលបងស្រី មេត្តាករុណា



អភិបូជាបុណ្យណូអែល នៅក្រចេះ



លោកអភិបាលចែកអំណោយដល់ទណ្ឌិតនៅតាកែវ



លោក. បូរី ធ្វើអគ្គសញ្ញាអាពាហ៍ពិពាហ៍ដល់បងប្អូនភាគតិច( ព្នង ) នៅមណ្ឌលគិរី




អបអរសាទរពិធីបុណ្យបញ្ចុះបឋមសិលា ព្រះវិហារ សន្តអន់ ដ្រេ និគម


អេម៉ាណូអែល
"សម្លេងពីព្រះសហគមន៍កាតូលិក"

| | |
|---|---|
| ភ្នំពេញ | : **FM 104 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| បាត់ដំបង | : **FM 91.0 Mhz** ម៉ោង ៧:៣០- ៨:៣០ រាល់ថ្ងៃ |
| សៀមរាប | : **FM 107.5 Mhz** ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ធំ | : **FM 103.5 Mhz** ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ចាម | : **FM 100.5 Mhz** ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| ព្រះសីហនុ | : **FM 92.5 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| កំពត | : **FM 93.25 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |

កម្មវិធីវិទ្យុ

" ខ្ញុំត្រូវការអ្នក "

ជាកម្មវិធីសម្រាប់យុវជន

ផ្សាយតាមរលកធាតុអាកាស FM99.5Mhz
រាល់ថ្ងៃអង្គារ
វេលាម៉ោង ១០:០០ - ១១:០០ព្រឹក